# សេវាកម្មក្រុមហ៊ុន SMG

# លក្ខខណ្ឌសេវាកម្ម

**កាលបរិច្ឆេទចូលជាធរមាន៖** មីនា 2018

លក្ខខណ្ឌសេវាកម្មទាំងអស់ រួមជាមួយនឹងគោលនយោបាយស្តីពីសិទ្ធិឯកជនភាពរបស់ក្រុមហ៊ុន SMG (ហៅកាត់ថា "**លក្ខខណ្ឌក្រុមហ៊ុន**") រៀបរាប់ពីលក្ខខណ្ឌនិងខចែងដែល ក្រុមហ៊ុន Service Management Group, LLC និងក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ខ្លួន (ហៅកាត់ថា "**ក្រុមហ៊ុន SMG**" ឬ "យើង" ឬ "ពួកយើង") ផ្តល់ជូនដល់អ្នកនូវការចូលទៅប្រើប្រាស់គេហទំព័រ សេវាកម្ម និងកម្មវិធីនានា រួមទាំងកម្មវិធីទូរសព្ទដៃ ដែលលក្ខខណ្ឌទាំងនេះត្រូវបានភ្ជាប់ជាមួយ ឬប្រើជាឯកសារយោង (ហៅជារួមថា "**សេវាកម្មក្រុមហ៊ុន SMG**")។

នៅមុនពេល ចូលទៅកាន់ឬប្រើប្រាស់សេវាកម្មក្រុមហ៊ុន SMG សូមអានលក្ខខណ្ឌក្រុមហ៊ុនដោយប្រុងប្រយ័ត្ន។ លក្ខខណ្ឌទាំងនេះ រួមបញ្ចូលនូវកិច្ចសន្យាផ្លូវច្បាប់រវាងក្រុមហ៊ុន SMG និងរូបអ្នកផ្ទាល់។

តាមរយៈការប្រើប្រាស់សេវាកម្មក្រុមហ៊ុន SMG អ្នកបានឯកភាពយល់ព្រមទៅនឹងលក្ខខណ្ឌក្រុមហ៊ុន និងបញ្ជាក់ថាអ្នកអាច និងមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តកិច្ចការនេះ។ ប្រសិនបើអ្នកកំពុងប្រើប្រាស់សេវាកម្មក្រុមហ៊ុន SMG ជំនួសមុខឲ្យនិយោជករបស់អ្នក ការទទួលយកលក្ខខណ្ឌទាំងអស់នេះ ត្រូវចាត់ទុកជាកិច្ចព្រមព្រៀងមួយរវាងនិយោជករបស់អ្នកជាមួយក្រុមហ៊ុន SMG ហើយអ្នកអះអាងនិងធានាថា អ្នកមានសិទ្ធិអំណាចក្នុងការភ្ជាប់កាតព្វកិច្ចនិយោជករបស់អ្នកទៅនឹងលក្ខខណ្ឌទាំងអស់នេះ។

| |
|---|
| កំណត់ចំណាំសំខាន់ៗ លក្ខខណ្ឌទាំងអស់នេះ រួមមានប្រការដែលកំណត់ពីទំនួលខុសត្រូវរបស់ក្រុមហ៊ុនយើងចំពោះរូបអ្នក និងតម្រូវឲ្យអ្នកធ្វើការដោះស្រាយវិវាទណាមួយជាមួយក្រុមហ៊ុនយើង តាមរយៈវិធានមជ្ឈត្តកម្មចុងក្រោយនិងមានភ្ជាប់កាតព្វកិច្ចដោយផ្អែកលើមូលដ្ឋានបណ្តឹងបុគ្គល និងមិនមែនជាផ្នែកមួយនៃបណ្តឹងជាក្រុម ឬតំណាងដោយអាណត្តិណាមួយនោះទេ។ សូមអាន "សុពលភាពនៃកិច្ចសន្យា ការបដិសេធការធានារ៉ាប់រង និងដែនកំណត់នៃទំនួលខុសត្រូវ" (ផ្នែក 7) និង "ដំណោះស្រាយវិវាទ" (ផ្នែក 9) ខាងក្រោម សម្រាប់ព័ត៌មានបន្ថែម។ |

**ប្រសិនបើអ្នកពុំយល់ស្របចំពោះលក្ខខណ្ឌទាំងអស់ដែលមានចែងនៅក្នុងលក្ខខណ្ឌសេវាកម្ម និងគោលនយោបាយសិទ្ធិឯកជនភាពរបស់ក្រុមហ៊ុន SMG អ្នកអាចបដិសេធមិនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG បាន។**



72528550_2

## 1. កំណែប្រែនានាចំពោះលក្ខខណ្ឌក្រុមហ៊ុន

កាលបរិច្ឆេទចូលជាធរមាននៃលក្ខខណ្ឌក្រុមហ៊ុន ត្រូវបានកំណត់នៅផ្នែកខាងលើនៃទំព័រគេហទំព័រនេះ។ ដោយសារយើងបន្ថែមកម្មវិធីថ្មីៗ យើងអាចធ្វើការកែប្រែចំពោះលក្ខខណ្ឌទាំងនេះបាន។ ក្រុមហ៊ុន SMG អាចធ្វើការផ្លាស់ប្ដូរលក្ខខណ្ឌទាំងនេះបាននៅគ្រប់ពេលវេលាទាំងអស់ដោយធ្វើបច្ចុប្បន្នភាពលើលក្ខខណ្ឌក្រុមហ៊ុន។ អ្នកត្រូវបានភ្ជាប់កាតព្វកិច្ចដោយការធ្វើកំណែប្រែនេះ អាស្រ័យហេតុនេះ អ្នកគប្បីចូលទៅមើលគេហទំព័រនេះក្នុងពេលណាមួយដើម្បីធ្វើការត្រួតពិនិត្យលើលក្ខខណ្ឌក្រុមហ៊ុន។ ការបន្តប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG បន្ទាប់ពី លក្ខខណ្ឌក្រុមហ៊ុនដែលបានផ្លាស់ប្ដូរណាមួយត្រូវបានចុះផ្សាយ មានន័យថាអ្នកបានទទួលយកលក្ខខណ្ឌក្រុមហ៊ុនដែលបានកែប្រែរួចនេះ។ លក្ខខណ្ឌក្រុមហ៊ុនដែលបានធ្វើការកែប្រែរួចជំនួសរាល់សំណៅឯកសារកិច្ចសន្យា សេចក្ដីជូនដំណឹង និងរបាយការណ៍ពីមុនមកទាំងអស់ ពាក់ព័ន្ធនឹងលក្ខខណ្ឌក្រុមហ៊ុន ប៉ុន្តែការផ្លាស់ប្ដូរនេះ នឹងមិនអនុវត្តធរមានឡើយ។

## 2. លក្ខខណ្ឌបន្ថែម

សេវាកម្មជាក់លាក់មួយចំនួនដែលបានផ្ដល់ជូនដោយ ឬតាមរយៈសេវាកម្មរបស់ក្រុមហ៊ុន SMG ដូចជាកម្មវិធីទូរសព្ទដៃ កម្មវិធីផ្ទាល់ ការប្រកួតប្រជែង និងសេវាកម្មនានា អាចត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌនិងខចែងបន្ថែមដែលបង្ហាញភ្ជាប់គ្នាជាមួយនឹងលក្ខខណ្ឌទាំងនោះ (ហៅកាត់ថា "លក្ខខណ្ឌបន្ថែម")។ អ្នកត្រូវមានការយល់ព្រមចំពោះលក្ខខណ្ឌបន្ថែមមុនពេលប្រើប្រាស់សេវាកម្មនោះ។ លក្ខខណ្ឌបន្ថែម ត្រូវយកមកអនុវត្តបន្ថែមលើលក្ខខណ្ឌក្រុមហ៊ុនទាំងនេះ។ ប្រសិនបើបញ្ញត្តិនៃលក្ខខណ្ឌបន្ថែម ផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃលក្ខខណ្ឌទាំងនេះ លក្ខខណ្ឌបន្ថែមទាំងនោះនឹងត្រូវមានអនុភាពលើបញ្ញត្តិដែលផ្ទុយគ្នាក្នុងលក្ខខណ្ឌទាំងនេះនៅត្រឹមកម្រិតនៃភាពផ្ទុយគ្នានោះតែប៉ុណ្ណោះ។

## 3. សិទ្ធិឯកជនភាព/សន្តិសុខ

នៅមុនពេលប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG សូមអានគោលការណ៍សិទ្ធិឯកជនភាពរបស់ក្រុមហ៊ុន SMG ដោយប្រុងប្រយ័ត្ន ដើម្បីធ្វើការសិក្សាអំពីទិន្នន័យផ្ទាល់ខ្លួនដែលក្រុមហ៊ុន SMG ប្រមូលបាននៅលើសេវាកម្មរបស់ក្រុមហ៊ុន SMG និងរបៀបដែលយើងវិភាគទិន្នន័យ និងមនុស្សដែលយើងត្រូវចែករំលែកទិន្នន័យផ្ទាល់ខ្លួននោះ។ អ្នកអាចស្វែងរកសំណៅថតចម្លងនៃគោលនយោបាយស្ដីពីសិទ្ធិឯកជនរបស់ក្រុមហ៊ុន SMG នៅ៖

## 4. ខ្លឹមសាររបស់ក្រុមហ៊ុន SMG

សេវាកម្មរបស់ក្រុមហ៊ុន SMG រួមបញ្ចូលនូវព័ត៌មាន រូបក្រាហ្វិច រូបថតស្នាដៃសិល្បៈ អត្ថបទ ខ្សែវីដេអូខ្លី បណ្ដុំទិន្នន័យ សូហ្វវែរ ខ្សែអាត់សំឡេងខ្លីៗ ពាណិជ្ជសញ្ញា ម៉ាកសេវាកម្ម កំណត់ត្រាសកម្មភាព ឈ្មោះពាណិជ្ជកម្ម និងខ្លឹមសារដទៃផ្សេងទៀត ដែលផ្ដល់ជូននៅក្នុងឬតាមរយៈសេវាកម្មរបស់ក្រុមហ៊ុន SMG (ហៅជារួមថា "**ខ្លឹមសារក្រុមហ៊ុន SMG**") ត្រូវបានកាត់កាប់ដោយក្រុមហ៊ុន SMG ក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់យើង ដៃគូអាជីវកម្ម ម្ចាស់អាជ្ញាប័ណ្ណ ឬក្រុមហ៊ុនតំណាង និងត្រូវបានការពារដោយសិទ្ធិថតចម្លង ប្រកាសនីយបត្រតក្កកម្មលើម៉ាក និងច្បាប់ដទៃផ្សេងទៀតរបស់សហរដ្ឋអាមេរិក និងបរទេស។ លើកលែងតែមានចែងនៅក្នុងផ្នែកអាជ្ញាប័ណ្ណកំណត់នៅផ្នែកខាងក្រោម ឬដូចបានតម្រូវដោយច្បាប់ជាធរមាន ពុំនោះ



72528550_2

សោតគ្មានសិទ្ធិថតចម្លង ពាណិជ្ជសញ្ញាច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ឬផ្នែកណាមួយនៃសេវាកម្មរបស់ក្រុមហ៊ុន SMG អាចនឹងត្រូវបានយកទៅប្រើប្រាស់ ផលិតឡើងវិញ ធ្វើទុតិយតា ថតចម្លង លក់ លក់បន្ត ចូលទៅប្រើប្រាស់ កែប្រែ ឬកេងចំណេញ ទោះទាំងស្រុង ឬដោយផ្នែកក្តី សម្រាប់គោលបំណងណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុននោះទេ។ ការប្រើប្រាស់ខ្លឹមសាររបស់ក្រុមហ៊ុន SMG ដោយគ្មានការអនុញ្ញាត អាចបំពានលើសិទ្ធិថតចម្លង ពាណិជ្ជសញ្ញា និងច្បាប់ដទៃផ្សេងទៀត។

ប្រសិនបើអ្នកយល់ព្រមចំពោះលក្ខខណ្ឌទាំងអស់នេះ (ក៏ដូចជាលក្ខខណ្ឌបន្ថែមដែលពាក់ព័ន្ធនឹងខ្លឹមសារជាក់លាក់របស់ក្រុមហ៊ុន SMG) ក្រុមហ៊ុន SMG ផ្តល់ជូនដល់អ្នកនូវអាជ្ញាប័ណ្ណផ្ទាល់ខ្លួន អាចដកហូតបាន មិនផ្តាច់មុខ មិនអាចផ្ទេរបាន និងមានលក្ខខណ្ឌកំណត់ (ដោយគ្មានសិទ្ធិក្នុងផ្តល់អាជ្ញាប័ណ្ណបន្ត) ដើម្បីចូលទៅកាន់និងប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG និងធ្វើការទាញយក ព្រីន និង/ឬថតចម្លងខ្លឹមសាររបស់ក្រុមហ៊ុន SMG ដោយផ្តាច់មុខសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងស្ថិតនៅក្រោមលក្ខខណ្ឌរបស់ក្រុមហ៊ុន។ អ្នកទទួលស្គាល់ថា ការសម្ងាត់ពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញាដែលភ្ជាប់ទៅនឹងសេវាកម្មរបស់ក្រុមហ៊ុន SMG មិនធ្លាប់ទទួលបាន ហើយនឹងមិនត្រូវបានផ្តល់អាជ្ញាប័ណ្ណ ឬបញ្ចេញឲ្យអ្នកបានដឹងនោះទេ។ អ្នកទទួលស្គាល់ថា លេខកូដ HTML ដែលក្រុមហ៊ុន SMG បង្កើតឡើងដើម្បីធ្វើគេហទំព័រសម្រាប់ សេវាកម្មនានា ត្រូវបានការពារដោយសិទ្ធិថតចម្លងរបស់ក្រុមហ៊ុន SMG។ គ្រប់សិទ្ធិទាំងអស់ដែលមិនមានផ្តល់ជូនច្បាស់លាស់នៅក្នុងទីនេះ ត្រូវបានរក្សាសិទ្ធិដោយក្រុមហ៊ុន SMG។

អ្នកបានឯកភាពថា លុះត្រាតែក្រុមហ៊ុន SMG ផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍ជូនដល់អ្នកជាមុនក្នុងការអនុវត្តបែបនេះ ពុំនោះសោត អ្នកនឹងមិនអាច៖

a. រួមបញ្ចូលនូវខ្លឹមសាររបស់ក្រុមហ៊ុន SMG ទៅក្នុងស្នាដៃណាមួយ (ដូចជាគេហទំព័រផ្ទាល់ខ្លួនរបស់អ្នក) ឬប្រើប្រាស់ខ្លឹមសារក្រុមហ៊ុន SMG នៅក្នុងលក្ខណៈឯកជនឬលក្ខណៈពាណិជ្ជកម្ម។
b. ធ្វើការផ្លាស់ប្តូរសេចក្តីជូនដំណឹងអំពីសិទ្ធិថតចម្លង ពាណិជ្ជសញ្ញា ឬសិទ្ធិកម្មសិទ្ធិបញ្ញាដទៃផ្សេងទៀត ដែលអាចជាផ្នែកមួយនៃខ្លឹមសាររបស់ក្រុមហ៊ុន SMG។
c. "តំណភ្ជាប់ជាក់លាក់" ទៅកាន់សេវាកម្មរបស់ក្រុមហ៊ុន SMG (ឧ.ទា. តំណភ្ជាប់ទៅកាន់គេហទំព័រណាមួយជាជាងគេហទំព័រផ្ទាល់ខ្លួននៃសេវាកម្មណាមួយរបស់ក្រុមហ៊ុន SMG)។

ពាណិជ្ជសញ្ញា ឡូហ្គោ និងម៉ាកសេវាកម្ម (ហៅកាត់ថា "ម៉ាក") ដែលបង្ហាញជូន ឬតាមរយៈសេវាកម្មរបស់ក្រុមហ៊ុន SMG ដែលត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុន SMG ឬភាគីទីបី។ អ្នកត្រូវបានហាមឃាត់ពីការប្រើប្រាស់ម៉ាកនេះ ដោយពុំមានការយល់ព្រមជាលាយលក្ខណ៍ពីក្រុមហ៊ុន SMG ឬភាគីទីបីណាមួយនោះទេ។ ប្រសិនបើអ្នកត្រូវការព័ត៌មានអំពីរបៀបក្នុងការទទួលបានការអនុញ្ញាតពីក្រុមហ៊ុន SMG ដើម្បីធ្វើការប្រើប្រាស់ខ្លឹមសាររបស់ក្រុមហ៊ុន SMG សូមអ៊ីម៉ែលទៅកាន់ privacyofficer@smg.com។

## 5. ការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG

5.1. <u>សិទ្ធិទទួលបាន៖</u> សេវាកម្មរបស់ក្រុមហ៊ុន SMG មិនផ្តោតលើការប្រើប្រាស់សម្រាប់កុមារមិនទាន់គ្រប់អាយុទទួលបានការអនុញ្ញាតដោយច្បាប់នៅក្នុងប្រទេសស្នាក់នៅរបស់ពួកគេ ដើម្បីផ្តល់ការអនុញ្ញាត



72528550_2

សម្រាប់វិភាគទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេនោះទេ។ ប្រសិនបើអ្នកមិនទាន់គ្រប់អាយុទទួលបានការអនុញ្ញាតនៅក្នុងប្រទេសរបស់អ្នកនោះទេ អ្នកពុំអាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG បានឡើយ។

5.2. <u>គណនីរបស់អ្នក៖</u> អ្នកអាចត្រូវបានតម្រូវដើម្បីបង្កើតគណនីមួយ (ហៅកាត់ថា "**គណនី**") ដើម្បីប្រើប្រាស់កម្មវិធីជាក់លាក់មួយនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។ អ្នកយល់ព្រមក្នុងការផ្តល់ជូន ថែទាំ និងធ្វើបច្ចុប្បន្នភាពព័ត៌មានជាក់លាក់ បច្ចុប្បន្ន និងពេញលេញអំពីខ្លួនអ្នកផ្ទាល់។ អ្នកយល់ព្រមមិនត្រូវក្លែងបន្លំខ្លួនជាបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយ ឬបង្ហាញព័ត៌មានមិនពិតអំពីអត្តសញ្ញាណរបស់អ្នក ឬការទាក់ទងជាមួយបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយ រួមទាំងការប្រើប្រាស់ឈ្មោះអ្នកប្រើប្រាស់ លេខកូដសម្ងាត់ ឬព័ត៌មានគណនីផ្សេងទៀតរបស់បុគ្គលណាម្នាក់ ឬឈ្មោះ លក្ខណៈស្រដៀងគ្នា សំឡេង រូបភាព ឬរូបថតរបស់បុគ្គលណាម្នាក់ផ្សេងទៀតនោះទេ។ អ្នកបានឯកភាពបន្ថែមទៀតក្នុងការជូនដំណឹងដល់ក្រុមហ៊ុនយើងឲ្យបានទាន់ពេលវេលានៅ privacyofficer@smg.com អំពីការប្រើប្រាស់ឈ្មោះអ្នកប្រើប្រាស់ លេខកូដសម្ងាត់ និងព័ត៌មានគណនីផ្សេងទៀតរបស់អ្នកដែលគ្មានការអនុញ្ញាតឬការបំពានផ្សេងទៀតលើផ្នែកសន្តិសុខដែលអ្នកបានដឹងពាក់ព័ន្ធនឹងសេវាកម្មរបស់ក្រុមហ៊ុន SMG។

**តាមរយៈការបង្កើតគណនីមួយ អ្នកយល់ព្រម ថាក្រុមហ៊ុន SMG អាច ទំនាក់ទំនងទៅអ្នកដោយប្រើអាសយដ្ឋានអ៊ីម៉ែលដែលអ្នកបានផ្តល់ជូននៅពេលបើកឲ្យដំណើរការ គណនីរបស់អ្នក។**

មិនត្រូវអនុញ្ញាតឲ្យអ្នកដទៃផ្សេងទៀតប្រើប្រាស់គណនីរបស់អ្នកនោះទេ។ អ្នកមានទំនួលខុសត្រូវចំពោះការប្រើប្រាស់ទាំងអស់លើគណនីរបស់អ្នក រួមទាំងការប្រើប្រាស់ណាមួយដោយអ្នកដទៃផ្សេងទៀតដែលអ្នកអនុញ្ញាតឲ្យចូលទៅប្រើប្រាស់គណនីរបស់អ្នក។

5.3. <u>ទំនួលខុសត្រូវរបស់អ្នក៖</u>

**ការព្រមព្រៀងរបស់អ្នកចំពោះការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG សម្រាប់តែគោលបំណងស្របច្បាប់តែប៉ុណ្ណោះ។** អ្នកបានឯកភាពថា អ្នកនឹងប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG សម្រាប់តែគោលបំណងស្របច្បាប់តែប៉ុណ្ណោះ។ អ្នកនឹងមិនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG ក្នុងលក្ខណៈណាមួយដែលអាចធ្វើឲ្យខូចខាត បញ្ឈប់ដំណើរការ មានបន្ទុកធ្ងន់ធ្ងរ ឬធ្វើឲ្យចុះខ្សោយដល់សើវើរ (server) ឬបណ្តាញអ៊ីនធឺណិតរបស់ក្រុមហ៊ុន SMG ឬបង្កការរំខានដល់ការប្រើប្រាស់និងការអាស្រ័យផលចំពោះសេវាកម្មរបស់ក្រុមហ៊ុន SMG ដោយភាគីដទៃផ្សេងទៀត។

**ការព្រមព្រៀងរបស់អ្នក មិនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG សម្រាប់គោលបំណងមិនស្របច្បាប់ ឬគោលបំណងដែលគ្មានការអនុញ្ញាត។** អ្នកបានយល់ស្របបន្ថែមទៀតថា អ្នកនឹងមិនប៉ុនប៉ងក្នុងការចូលទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវសេវាកម្មរបស់ក្រុមហ៊ុន SMG គណនីអ្នកប្រើប្រាស់ដទៃផ្សេងទៀត ឬប្រព័ន្ធកុំព្យូទ័រ ឬបណ្តាញអ៊ីនធឺណិតរបស់ក្រុមហ៊ុន SMG តាមរយៈការលួចចូល (hacking) ការលួចលេខកូដសម្ងាត់ ឬតាមមធ្យោបាយដទៃផ្សេងទៀត។ ដោយពុំមានកំណត់ចំពោះ

លក្ខខណ្ឌដែលបានចែងពីខាងដើម អ្នកបានយល់ព្រមថា អ្នកមិនត្រូវ (ហើយអ្នកមិនត្រូវលើកទឹកចិត្ត ឬ អនុញ្ញាតឲ្យភាគីទីបីណាមួយ)៖

a. ធ្វើការថតចម្លង កែប្រែ ប្រើប្រាស់ បកប្រែ ផលិតតាមស្នាដៃ ផ្លាស់ប្តូរកូដ ឬប៉ុនប៉ងដើម្បីទទួលបាន ឬអាចចូលទៅប្រើប្រាស់ផ្នែកណាមួយនៃសេវាកម្មរបស់ក្រុមហ៊ុន SMG ឬខ្លឹមសាររបស់ក្រុមហ៊ុន SMG។

b. ដកយកចេញនូវសិទ្ធិថតចម្លង ពាណិជ្ជសញ្ញា ឬសេចក្តីជូនដំណឹងអំពីសិទ្ធិជាម្ចាស់កម្មសិទ្ធិដទៃផ្សេងទៀតដែលមាននៅក្នុងសេវាកម្មរបស់ក្រុមហ៊ុន SMG ឬខ្លឹមសាររបស់ក្រុមហ៊ុន SMG។

c. កេងយកផលប្រយោជន៍ ធ្វើឲ្យដំណើរការមិនកើត ឬបង្កការរំខានដល់បញ្ហាសន្តិសុខ ឬកម្មវិធីសម្រាប់បង្ការការលួចបន្លំនៃសេវាកម្មរបស់ក្រុមហ៊ុនយើង ឬកម្មវិធីនានាដែលបង្ការ ឬរឹងបន្តឹងការប្រើប្រាស់ ឬការថតចម្លងខ្លឹមសារណាមួយរបស់ក្រុមហ៊ុន SMG ឬការបង្ខំការរឹតបន្តឹងចំពោះការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនយើង ឬខ្លឹមសាររបស់ក្រុមហ៊ុន SMG។

d. ការប្រើប្រាស់ពុំបានត្រឹមត្រូវនូវសេវាកម្មក្រុមហ៊ុនដោយមានចេតនាបញ្ចូលកម្មវិធីមេរោគនានា កម្មវិធី Trojans កម្មវិធីមេរោគដង្កូវ (worms) កម្មវិធីមេរោគ (logic bombs) កម្មវិធីឃ្លាំមើល (spyware) កម្មវិធីមេរោគ (malware) ឬកម្មវិធីមេរោគដទៃផ្សេងទៀត ឬសម្ភារៈដែលមានគ្រោះថ្នាក់ផ្នែកបច្ចេកវិទ្យា។

e. ប្រើប្រាស់រ៉ូបូត កម្មវិធីស្ពៃដឺ (spider) ការស្រាវជ្រាវគេហទំព័រ/កម្មវិធីទទួលបានព័ត៌មាន ឬឧបករណ៍អេឡិចត្រូនិកស្វ័យប្រវត្តិដទៃផ្សេងទៀត ដំណើរការឬមធ្យោបាយដើម្បីចូលទៅប្រើប្រាស់ ទទួលបាន ឬចាប់យក ឬធ្វើឧបសម្ព័ន្ធផ្នែកណាមួយនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។

f. ជួលរយៈពេលខ្លី ជួលរយៈពេលវែង លក់ ផ្តល់អាជ្ញាប័ណ្ណបន្ត អនុប្បទាន ចែកចាយ បោះពុម្ពផ្សាយ ផ្ទេរ ឬធ្វើឲ្យសេវាកម្មរបស់ក្រុមហ៊ុន SMG អាចស្វែងរកបាន ឬកម្មវិធីណាមួយ ឬមុខងារនៃសេវាកម្មរបស់ក្រុមហ៊ុន SMG ទៅឲ្យភាគីទីបីសម្រាប់មូលហេតុណាមួយ រួមទាំងការធ្វើឲ្យសេវាកម្មរបស់ក្រុមហ៊ុន SMG អាចស្វែងរកបាននៅលើបណ្តាញណាមួយ ដែលវាអាចមានសមត្ថភាពក្នុងការចូលទៅប្រើប្រាស់បានដោយឧបករណ៍អេឡិចត្រូនិកច្រើនជាងមួយនៅគ្រប់ពេលពេលវេលាទាំងអស់។

g. កំណែប្រែទម្រង់ ឬគ្រោងនៃផ្នែកណាមួយនៃគេហទំព័រដែលជាផ្នែកនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។

h. បង្កើតគណនីលើសពីមួយដោយមធ្យោបាយស្វ័យប្រវត្តិកម្ម ឬក្នុងគោលបំណងបោកបញ្ឆោត ឬកន្លែងបន្លំណាមួយ។ ឬ

i. ប្រមូល ឬរក្សាទុកព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ដទៃផ្សេងទៀតណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកប្រើប្រាស់ទាំងនោះ។

**ផលប៉ះពាល់នៃការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់ពុំបានត្រឹមត្រូវនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។** អ្នកឯកភាពថា សិទ្ធិរបស់អ្នកក្នុងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG នឹងបញ្ចប់ភ្លាមៗ នៅពេលអ្នកបំពានលើវិធានទាំងនេះ ហើយថា ក្រុមហ៊ុន SMG មានឆន្ទានុសិទ្ធិក្នុងការបញ្ចប់ការចូលទៅប្រើប្រាស់សេវាកម្មក្រុមហ៊ុន SMG ដោយពុំចាំបាច់មានការជូនដំណឹងបន្ថែមឡើយ ប្រសិនបើអ្នកបំពានលើលក្ខខណ្ឌតម្រូវ ឬការហាមឃាត់ណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌ

ក្រុមហ៊ុន ឬនៅក្នុងលក្ខខណ្ឌបន្ថែមដែលមានជាធរមានណាមួយ។ អ្នកបានឯកភាពបន្ថែមទៀតក្នុងការប្រគល់ត្រឡប់ទៅវិញ ឬបំផ្លាញចោលនូវសំណៅថតចម្លងនៃឯកសារនៅលើគេហទំព័រដែលអ្នកបានបង្កើត ប្រសិនបើក្រុមហ៊ុនយើងស្នើសុំឲ្យអ្នកធ្វើការលុបចោល។

ការប្រើប្រាស់ដែលគ្មានការអនុញ្ញាត និងការប្រើប្រាស់ពុំបានត្រឹមត្រូវនៃសេវាកម្មរបស់ក្រុមហ៊ុន SMG ត្រូវបានហាមឃាត់ជាដាច់ខាត ហើយអ្នកត្រូវប្រឈមមុខទៅនឹងការទាមទារសំណងរដ្ឋប្បវេណីសម្រាប់ការខូចខាត និង/ឬបណ្តឹងព្រហ្មទណ្ឌ។ ក្រុមហ៊ុន SMG រក្សាសិទ្ធិក្នុងការរាយការណ៍អំពីការបំពានលើលក្ខខណ្ឌក្រុមហ៊ុន ឬការប្រើប្រាស់ដែលគ្មានការអនុញ្ញាត ឬការប្រើប្រាស់ពុំបានត្រឹមត្រូវនៃសេវាកម្មរបស់ក្រុមហ៊ុន SMG ទៅកាន់អាជ្ញាធរអនុវត្តច្បាប់។ នៅក្នុងករណីដែលមានការប្រើប្រាស់គ្មានការអនុញ្ញាត ឬការប្រើប្រាស់ពុំបានត្រឹមត្រូវនៃសេវាកម្មរបស់ក្រុមហ៊ុន SMG សិទ្ធិរបស់អ្នកក្នុងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG នឹងត្រូវបញ្ចប់ភ្លាមៗ ហើយក្រុមហ៊ុន SMG អាចបិទមិនឲ្យអ្នកចូលទៅប្រើប្រាស់សេវាកម្មណាមួយរបស់ក្រុមហ៊ុន SMG ដោយគ្មានការជូនដំណឹងនោះទេ។
**ទំនួលខុសត្រូវរបស់អ្នកសម្រាប់ថ្លៃចំណាយ ថ្លៃសេវា និងថ្លៃចំណាយដទៃផ្សេងទៀតដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG (រួមទាំងថ្លៃសេវាផ្ញើសារជាអក្សរផងដែរ)។** អ្នកមានទំនួលខុសត្រូវផ្តាច់មុខសម្រាប់ថ្លៃបន្ទុក ថ្លៃសេវា និងថ្លៃចំណាយដទៃផ្សេងទៀតណាមួយឬទាំងអស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG។ ប្រសិនបើអ្នកចូលទៅកាន់ និងប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG នៅលើទូរសព្ទស្មាតហ្វូន ថេបប្លេត ឬឧបករណ៍ចល័តដទៃផ្សេងទៀតរបស់អ្នក អ្នកត្រូវមានសេវាអ៊ីនធឺណិតឥតខ្សែតាមរយៈប្រព័ន្ធ Wi-Fi ឬក្រុមហ៊ុនផ្តល់សេវាទូរសព្ទដែលចូលរួម។ សេវាជាក់លាក់មួយចំនួន អាចតម្រូវឲ្យមានសមត្ថភាពបញ្ជូនសារជាអក្សរ (SMS ឬ MMS)។ អ្នកយល់ព្រមថា អ្នកមានទំនួលខុសត្រូវផ្តាច់មុខសម្រាប់សារគ្រប់ប្រភេទ និងការកាត់ប្រាក់ក្នុងទិន្នន័យដោយក្រុមហ៊ុនផ្តល់សេវាទូរសព្ទរបស់អ្នក។ យើងពុំបានកំណត់ការកាត់ប្រាក់ដាច់ដោយឡែកសម្រាប់សេវាផ្ញើសារជាអក្សរ ដែលយើងអាចផ្តល់ជូននោះទេ ប៉ុន្តែយើងអាចអនុវត្តអត្រាតម្លៃសារនិងទិន្នន័យ។ រាល់ថ្លៃចំណាយទាំងអស់ ត្រូវទូទាត់ និងត្រូវបង់ប្រាក់ទៅឲ្យក្រុមហ៊ុនផ្តល់សេវាទូរសព្ទរបស់អ្នក។ សូមទំនាក់ទំនងក្រុមហ៊ុនផ្តល់សេវាទូរសព្ទរបស់អ្នកសម្រាប់គម្រោងតម្លៃនិងព័ត៌មានលម្អិត។ ក្រុមហ៊ុន SMG មិនទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការផ្ញើសារជាអក្សរ ឬការខកខានណាមួយក្នុងការផ្តល់សារជាអក្សរនោះទេ ដោយសារការផ្តល់សារនេះគឺអាស្រ័យលើដំណើរការដ៏មានសិទ្ធភាពនៃការបញ្ជូនព័ត៌មានរបស់ក្រុមហ៊ុនផ្តល់សេវាទូរសព្ទរបស់អ្នក។ សារជាអក្សរ អាចនឹងមិនមានលទ្ធភាពប្រើប្រាស់បាននៅគ្រប់ទីកន្លែងគ្រប់ពេលវេលាទាំងអស់នោះទេ។

**ផលវិបាកនៃការព្រមព្រៀងរបស់អ្នកក្នុងការជ្រើសរើសដើម្បីទទួលសារជាអក្សរ។** នៅពេលដែលអ្នកជ្រើសរើសទទួលយកសារជាអក្សរពីក្រុមហ៊ុនយើង ភាពញឹកញាប់នៃសារជាអក្សរដែលយើងផ្ញើទៅអ្នកនឹងអាស្រ័យលើប្រតិបត្តិការរបស់អ្នកជាមួយក្រុមហ៊ុនយើង។ **តាមរយៈការយល់ព្រមដើម្បីទទួលយកសារជាអក្សរ អ្នកដឹងនិងយល់ព្រមថា ក្រុមហ៊ុន SMG អាចប្រើប្រាស់ប្រព័ន្ធហៅទូរសព្ទដោយស្វ័យប្រវត្តិដើម្បីផ្ញើសារជាអក្សរទៅអ្នក ហើយអ្នកបន្តយល់ដឹងទៀតថា ការយល់ព្រមទទួលយកសារជា**

**អក្សររបស់អ្នក គឺពុំមែនជាការតម្រូវចាំបាច់ដើម្បីឲ្យអ្នកទទួលបានការអនុញ្ញាតដើម្បីទិញទំនិញឬសេវាកម្មក្រុមហ៊ុននោះទេ។**

5.4. <u>ការផ្តល់ព័ត៌មាន</u>។ ពីពេលមួយទៅពេលមួយ ក្រុមហ៊ុន SMG អាចផ្តល់ឱកាសជាច្រើនសម្រាប់អ្នក និងអ្នកប្រើប្រាស់ដទៃផ្សេងទៀតដើម្បីធ្វើការបង្ហោះ ឬបញ្ជូនការកំណត់ពិន្ទុ មិតិស្នើសុំ មតិកែលម្អលើវីដេអូ គំនិតយោបល់ កំណត់សម្គាល់ គោលគំនិត ឬព័ត៌មាននិងឯកសារដទៃផ្សេងទៀតទៅកាន់ ឬតាមរយៈសេវាកម្មក្រុមហ៊ុន SMG (ហៅជារួមថា " **ការផ្តល់ព័ត៌មាន**")។

អ្នកនឹងត្រូវមានទំនួលខុសត្រូវផ្តាច់មុខចំពោះការផ្តល់ព័ត៌មានរបស់អ្នក និងផលវិបាកនានាពីការប្រគល់ និងបង្ហោះការផ្តល់ព័ត៌មាននេះ។ អ្នកនឹងត្រូវមានទំនួលខុសត្រូវផ្តាច់មុខសម្រាប់ការខូចខាតណាមួយដែលបង្កឡើងដោយការបំពានលើសិទ្ធិថតចម្លង សិទ្ធិម្ចាស់កម្មសិទ្ធិ ឬគ្រោះថ្នាក់ដទៃផ្សេងទៀតណាមួយកើតចេញពីការផ្តល់ព័ត៌មានរបស់អ្នក។ នៅពេលប្រគល់ ឬបង្ហោះខ្លឹមសារផ្តល់ព័ត៌មាននេះ អ្នកត្រូវកំណត់តាមលទ្ធភាពដែលអាចធ្វើទៅបាននូវចំនួនទិន្នន័យផ្ទាល់ខ្លួនដែលអ្នកផ្តល់ឲ្យ ដោយសារការផ្តល់ព័ត៌មាននេះ អាចធ្វើការតភ្ជាប់ទៅអ្នកបានអាស្រ័យទៅលើព័ត៌មានលម្អិតដែលអ្នកបានផ្តល់ជូន។

តាមរយៈការផ្ញើ ការបង្ហោះ ឬការបញ្ជូនការផ្តល់ព័ត៌មានទៅកាន់ក្រុមហ៊ុន SMG (និង/ឬបុគ្គលដែលទទួលបានការចាត់តាំងរបស់យើង) ឬផ្នែកណាមួយនៃសេវាកម្មរបស់ក្រុមហ៊ុន SMG អ្នកបានផ្តល់សិទ្ធិជាស្វ័យប្រវត្តិ ឬធានាថា អ្នកនិងម្ចាស់នៃឯកសារដែលអ្នកបានប្រគល់ជូន ពិតជាបានផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុន SMG និងអ្នកទទួលបានការចាត់តាំងរបស់ក្រុមហ៊ុននូវសិទ្ធិជាសកល មិនផ្តាច់មុខ សិទ្ធិផ្តល់អាជ្ញាប័ណ្ណបន្ត (តាមរយៈកម្រិតសេវាកម្មជាច្រើន) សិទ្ធិដែលអាចផ្ទេរបន្តបាន សិទ្ធិប្រើប្រាស់ដោយមិនជាប់កម្មសិទ្ធិបញ្ញា សិទ្ធិជាអចិន្ត្រៃយ៍ និងសិទ្ធិដែលមិនអាចដកហូតបាន ដើម្បីប្រើប្រាស់ ផលិតឡើងវិញ ផ្តល់អាជ្ញាប័ណ្ណបន្ត (តាមរយៈកម្រិតសេវាកម្មជាច្រើន) ចែកចាយបន្ត បង្កើតស្នាដៃចេញពី ឬអនុវត្ត ឬបញ្ចូលនូវការផ្តល់ព័ត៌មានរបស់អ្នក (ទាំងស្រុង ឬដោយផ្នែក) នៅក្នុងសារព័ត៌មានណាមួយដែលមានគេស្គាល់ក្នុងពេលបច្ចុប្បន្ននេះ ឬត្រូវបានបង្កើតឡើងនៅពេលក្រោយទៀត សម្រាប់គោលបំណងណាមួយជាលក្ខណៈពាណិជ្ជកម្មឬផ្សេងទៀត ដោយពុំមានការទូទាត់សំណងជូនអ្នកនោះទេ។ ក្នុងន័យម្យ៉ាងទៀត ក្រុមហ៊ុន SMG មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការប្រើប្រាស់ការផ្តល់ព័ត៌មានរបស់អ្នក -- រួមទាំងការផលិតសារឡើងវិញ ការបញ្ចេញព័ត៌មាន ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយការផ្តល់ព័ត៌មានរបស់អ្នក -- នៅគ្រប់ទីកន្លែង គ្រប់ពេលវេលា តាមមធ្យោបាយណាមួយ និងសម្រាប់គោលបំណងណាមួយដោយពុំចាំបាច់បង់ថ្លៃសេវាឬជាប់កាតព្វកិច្ចណាមួយជាមួយអ្នកនោះទេ។ អ្នកក៏បានអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្សេងទៀតចូលទៅកាន់ ពិនិត្យមើល រក្សាទុក ឬបង្កើតឡើងវិញនូវការផ្តល់ព័ត៌មានរបស់អ្នកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះទេ។ អ្នកបានផ្តល់សិទ្ធិដល់ក្រុមហ៊ុន SMG (និង/ឬអ្នកដែលទទួលបានការចាត់តាំងពីក្រុមហ៊ុន) ដើម្បីធ្វើការប្រើប្រាស់ការផ្តល់ព័ត៌មានរបស់អ្នកសម្រាប់គោលបំណងណាមួយនៅគ្រប់ទីកន្លែង។ មិនថាស្ថិតក្រោមកាលៈទេសៈណានោះទេ អ្នកពុំមានសិទ្ធិទទួលបានការទូទាត់ប្រាក់ប្រភេទណាមួយឡើយ ប្រសិនបើក្រុមហ៊ុន SMG

(និង/ឬអ្នកដែលទទួលបានការចាត់តាំងពីក្រុមហ៊ុន) ប្រើប្រាស់ការផ្តល់ព័ត៌មានណាមួយរបស់អ្នក។ គ្រប់ការផ្តល់ព័ត៌មានទាំងអស់ ត្រូវចាត់ទុកថាមិនមែនជាការសម្ងាត់ និងមិនមានម្ចាស់កម្មសិទ្ធិឡើយ។

ការផ្តល់ព័ត៌មានដែលអ្នកបង្ហោះ អាចនឹងត្រូវបង្ហាញជាសាធារណៈ។ អ្នកទទួលស្គាល់ថា អ្នកពុំមានការរំពឹងទុកពីសិទ្ធិឯកជនភាពពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានណាមួយរបស់អ្នកនោះទេ។ អ្នកបន្តទទួលស្គាល់ទៀតថា អ្នកបានផ្តល់ព័ត៌មាននោះដោយស្ម័គ្រចិត្ត និងទទួលយកហានិភ័យដោយខ្លួនឯង។ អ្នកគប្បីត្រូវមានសុភវិនិច្ឆ័យត្រឹមត្រូវ នៅពេលបង្ហោះព័ត៌មាន កំណត់សម្គាល់ ឬខ្លឹមសារដទៃផ្សេងទៀតពាក់ព័ន្ធនឹងក្រុមហ៊ុន SMG អតិថិជនរបស់ក្រុមហ៊ុន SMG ឬអង្គភាព ឬបុគ្គលដទៃផ្សេងទៀត។ អ្នកអាចត្រូវមានទំនួលខុសត្រូវផ្លូវច្បាប់សម្រាប់ការខូចខាតណាមួយដែលកើតមានចំពោះអ្នកប្រើប្រាស់ក្រុមហ៊ុន SMG ឬភាគីទីបី ដែលបង្កឡើងដោយការការផ្តល់ព័ត៌មានណាមួយរបស់អ្នកដែលមានលក្ខណៈជាការបរិហារកេរ្តិ៍ ឬអាចចោទប្រកាន់តាមផ្លូវច្បាប់បាន។ នៅពេលបង្ហោះការផ្តល់ព័ត៌មាន អ្នកអាចជ្រើសរើសដាក់តំណភ្ជាប់ការផ្តល់ព័ត៌មានរបស់អ្នកជាមួយនឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក ឬឈ្មោះហៅក្រៅណាមួយ លើកលែងតែច្បាប់ជាធរមាននៅក្នុងប្រទេសដែលអ្នកស្នាក់នៅតម្រូវឲ្យមានការអនុវត្តផ្សេងពីនេះ។

ក្រុមហ៊ុន SMG ពុំទំនួលខុសត្រូវផ្លូវច្បាប់សម្រាប់ការប្រគល់ព័ត៌មានណាមួយធ្វើឡើងដោយអ្នកប្រើប្រាស់នោះទេ បើទោះបីជាការផ្តល់ព័ត៌មាននោះមានលក្ខណៈជាការបរិហារកេរ្តិ៍ ឬអាចចោទប្រកាន់បានក៏ដោយ។ ក្រុមហ៊ុន SMG ពុំទទួលខុសត្រូវ ឬពុំគាំទ្រចំពោះទស្សនៈយល់ឃើញ គំនិតយោបល់ ឬអនុសាសន៍នានាដែលបានបង្ហោះ ឬប្រគល់ជូនទៅកាន់ ឬតាមរយៈសេវាកម្មក្រុមហ៊ុន SMG នោះទេ។ ជាពិសេស ក្រុមហ៊ុន SMG សូមបដិសេធមិនទទួលខុសត្រូវទោះដោយផ្នែកឬទាំងស្រុងក្តីចំពោះការប្រគល់ព័ត៌មានបែបនោះទេ។ ក្រុមហ៊ុន SMG ពុំបានបញ្ជាក់ ឬផ្ទៀងផ្ទាត់បុគ្គលិកលក្ខណៈ សារតារ ឬសមត្ថភាពរបស់អ្នកប្រើប្រាស់ ឬព័ត៌មានដែលពួកគេបង្ហោះទៅកាន់ ឬតាមរយៈសេវាកម្មណាមួយរបស់ក្រុមហ៊ុន SMG នោះទេ។ ដូចនេះ ក្រុមហ៊ុន SMG សូមទទូចឲ្យអ្នកមានការគិតពិចារណា និងមានសុភវិនិច្ឆ័យក្នុងការរៀបចំការផ្តល់ព័ត៌មានរបស់អ្នក។

តាមរយៈការបង្ហោះការផ្តល់ព័ត៌មានណាមួយ អ្នកយល់ព្រម អះអាង និងធានាថា ការផ្តល់ព័ត៌មានរបស់អ្នកៈ

a. ពិតជាត្រឹមត្រូវ និងច្បាស់លាស់ប្រាកដមែន។
b. មានជាប់ពាក់ព័ន្ធទៅនឹងប្រធានបទ ឬមូលបទនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។
c. ពុំរំលោភបំពាន ពុំមានលក្ខណៈមិនសមរម្យ ឬបំពានដល់សិទ្ធិថតចម្លង ពាណិជ្ជសញ្ញា ប្រកាសនីយបត្រតក្កកម្ម ខ្លឹមសារអត្ថបទ ការសម្ងាត់ពាណិជ្ជកម្ម សិទ្ធិឯក សាធារណៈ ម្ចាស់កម្មសិទ្ធិ សិទ្ធិក្នុងកិច្ចសន្យា ឬសិទ្ធិដទៃផ្សេងទៀតរបស់ភាគីទីបីនោះទេ។

d. ពុំមានព័ត៌មានណាមួយដែលកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់ ឬព័ត៌មានដែលអាចរួមបញ្ចូលនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់ លើកលែងតែអ្នកមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីបុគ្គលរូបនោះទេជាមុន។
e. ពុំមានការទាមទារដែលពុំមានការចាំបាច់ណាមួយអំពីភាគីទីបី ឬផលិតផល ឬសេវាកម្មរបស់ភាគីទីបី។
f. ពុំមានការមតិយោបល់មានលក្ខណៈជាការមួលបង្កាច់ ការបង្ខូចកេរ្តិ៍ឈ្មោះ មិនពិត បំភាន់ អសុរស អាសអាភាស រូបភាពអាសអាភាស អំពើហិង្សា ភាពងប់ងល់នឹងសាសនា គ្មានការលាក់បាំងផ្លូវភេទ មានការស្អប់ ការបំពារបំពាន ការគំរាមកំហែង ការបៀតបៀន ការប្រឆាំងនឹងសង្គម ឬខ្លឹមសារដទៃផ្សេងទៀតអាចបង្កគ្រោះថ្នាក់ ឬអាចរំពឹងថានឹងបង្កគ្រោះថ្នាក់ដល់បុគ្គលឬអង្គភាពណាមួយ។
g. ពុំមានលក្ខណៈខុសច្បាប់ និងពុំបានលើកទឹកចិត្ត ឬគាំទ្រដល់សកម្មភាពខុសច្បាប់ ឬការពិភាក្សាអំពីសកម្មភាពខុសច្បាប់ជាមួយនឹងគោលបំណងក្នុងការប្រព្រឹត្តអំពើខុសច្បាស់ទាំងនោះ។
h. ពុំមានលក្ខណៈពាណិជ្ជកម្ម ឬពាក់ព័ន្ធនឹងអាជីវកម្ម និងពុំឃោសនាពាណិជ្ជកម្ម ឬផ្តល់ការលក់ផលិតផល ឬសេវាកម្មណាមួយ (មិនថាសម្រាប់ប្រាក់ចំណេញ ឬអត់នោះទេ) ឬដើម្បីឃោសនាដល់អ្នកដទៃ (រួមទាំងការឃោសនាសម្រាប់ការបរិច្ចាគ ឬវិភាគទានដទៃផ្សេងទៀត)។
i. ពុំមានផ្ទុកទៅដោយមេរោគ ឬសមាសធាតុគ្រោះថ្នាក់ផ្សេងទៀត ឬធ្វើឲ្យភាពរញ៉េរញ៉ៃ ខូចខាត ឬបំផ្លាញដល់សេវាកម្មរបស់ក្រុមហ៊ុន SMG ឬបណ្តាញភ្ជាប់ណាមួយ ឬការរំខានដល់ការប្រើប្រាស់ឬការអាស្រ័យផលរបស់បុគ្គល ឬអង្គភាពដទៃផ្សេងទៀតនៃសេវាកម្មរបស់ក្រុមហ៊ុន SMG។ និង
j. អនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ វិធាន គោលនយោបាយ និងលក្ខខណ្ឌកិច្ចសន្យាដែលមានជាធរមាន ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានរបស់អ្នក និងពាក់ព័ន្ធនឹងសេវាកម្មរបស់ក្រុមហ៊ុន SMG ដែលអ្នកបានបង្ហោះព័ត៌មាន ឬផ្តល់នូវព័ត៌មានពាក់ព័ន្ធ រួមទាំងការរឹតបណ្តឹងអំពីអាយុផងដែរ។

អ្នកបានទទួលស្គាល់ និងឯកភាពថា ក្រុមហ៊ុន SMG មានសិទ្ធិ (តែមិនមែនជាកាតព្វកិច្ច) ក្នុងការកែប្រែដកចេញ ឬបដិសេធមិនបង្ហោះ ឬអនុញ្ញាតឲ្យមានការបង្ហោះនូវការផ្តល់ព័ត៌មានណាមួយនោះទេ។ ក្រុមហ៊ុន SMG ពុំមានទទួលខុសត្រូវ និងមិនទទួលខុសត្រូវចំពោះការផ្តល់ព័ត៌មានណាមួយដែលបានបង្ហោះដោយអ្នក ឬភាគីទីបីណាមួយនោះទេ។ ក្រុមហ៊ុន SMG មិនអាចឬពុំធានាថា គ្រប់អ្នកប្រើប្រាស់ទាំងអ្នកសុទ្ធតែបានអនុលោមទៅតាមបញ្ញត្តិទាំងនេះនោះទេ ហើយរវាងអ្នកនិងក្រុមហ៊ុន SMG អ្នកទទួលយកហានិភ័យនៃគ្រោះថ្នាក់ទាំងអស់ ឬរបួសស្នាមដែលបង្កឡើងពីការមិនអនុវត្តទៅតាមលក្ខខណ្ឌទាំងនេះ។

ក្រុមហ៊ុន SMG សូមលើកទឹកចិត្តអ្នកឲ្យកាត់បន្ថយការបញ្ចេញទិន្នន័យផ្ទាល់ខ្លួនឲ្យបានតិចតួចបំផុតនៅក្នុងការផ្តល់ព័ត៌មានរបស់អ្នក ដោយសារមនុស្សដទៃផ្សេងទៀតអាចមើលឃើញ និងប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួននៅក្នុងការផ្តល់ព័ត៌មានរបស់អ្នក។ ក្រុមហ៊ុន SMG ពុំទទួលខុសត្រូវចំពោះព័ត៌មានណាមួយដែលអ្នកបានជ្រើសរើសដើម្បីបង្ហាញតាមរយៈការផ្តល់ព័ត៌មានរបស់អ្នកនោះទេ។

## 6. គេហទំព័រ និងសេវាកម្មរបស់ភាគីទីបី

សេវាកម្មរបស់ក្រុមហ៊ុន SMG អាចមានផ្ទុកទៅដោយដំណភ្ជាប់ទៅកាន់គេហទំព័រសេវាកម្មរបស់ភាគីទីបី រួមបញ្ចូលទាំងបណ្ដាញសារព័ត៌មានសង្គម (ហៅជារួមថា "**សេវាតំណភ្ជាប់**")។ សេវាតំណភ្ជាប់ មិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន SMG នោះទេ ហើយក្រុមហ៊ុន SMG មិនទទួលខុសត្រូវចំពោះសេវាតំណភ្ជាប់ ឬសម្រាប់ព័ត៌មានណាមួយ ឬឯកសារណាមួយ ឬទម្រង់ណាមួយនៃការផ្ដល់ព័ត៌មានដែលទទួលបានពីសេវាតំណភ្ជាប់ណាមួយឡើយ។ ភាពផ្ដាច់មុខនៃតំណភ្ជាប់ ពុំមិនសំដៅដល់ការគាំទ្ររបស់ក្រុមហ៊ុន SMG ចំពោះសេវាតំណភ្ជាប់ ឬការជាប់ព័ន្ធណាមួយជាមួយប្រតិបត្តិករនៃសេវាតំណភ្ជាប់នោះទេ។ ក្រុមហ៊ុន SMG ពុំបានធ្វើការស៊ើបអង្កេត បញ្ជាក់ ឬគ្រប់គ្រងលើសេវាតំណភ្ជាប់នោះទេ។ ក្រុមហ៊ុន SMG ភ្ជាប់តំណភ្ជាប់ទៅកាន់សេវាតំណភ្ជាប់សម្រាប់ភាពងាយស្រួលរបស់អ្នកតែប៉ុណ្ណោះ។ អ្នកចូលទៅប្រើប្រាស់សេវាតំណភ្ជាប់ដោយប្រឈមនឹងហានិភ័យដោយខ្លួនឯង។

## 7. សុពលភាពនៃកិច្ចសន្យា ការបដិសេធចំពោះការធានារ៉ាប់រង និងដែនកំណត់នៃទំនួលខុសត្រូវ

ក្រុមហ៊ុន SMG ធានាថា ក្រុមហ៊ុន SMG មានសុពលភាពក្នុងការចុះកិច្ចសន្យាក្នុងលក្ខខណ្ឌរបស់ក្រុមហ៊ុន និងមានអំណាចផ្លូវច្បាប់ដើម្បីធ្វើការចុះកិច្ចសន្យានេះ។ អ្នកធានាថា អ្នកមានសុពលភាពក្នុងការចុះកិច្ចសន្យាក្នុងលក្ខខណ្ឌរបស់ក្រុមហ៊ុន និងមានអំណាចផ្លូវច្បាប់ដើម្បីធ្វើការចុះកិច្ចសន្យានេះ។

**លើកលែងតែមានចែកយ៉ាងច្បាស់នៅផ្នែកខាងលើ សេវាកម្មរបស់ក្រុមហ៊ុន SMG ត្រូវបានផ្ដល់ជូន "តាមលក្ខណៈដែលស្រាប់" និង "តាមលក្ខខណ្ឌដែលមាន" ដោយគ្មានការធានា ការបញ្ជាក់ ឬការបកស្រាយណាមួយនោះទេ**។ ក្រុមហ៊ុន SMG ពុំបានធ្វើការអះអាង ឬការធានាចំពោះភាពត្រឹមត្រូវ ភាពអាចជឿទុកចិត្តបាន ភាពពេញលេញ ឬពេលវេលានៃខ្លឹមសាររបស់ក្រុមហ៊ុន SMG ឬលទ្ធផលដែលអាចទទួលបានពីការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG និងខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG។ ការប្រើប្រាស់សេវាកម្ម និងខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG គឺជាប្រឈមនឹងហានិភ័យដោយខ្លួនអ្នកផ្ទាល់។ ការផ្លាស់ប្ដូរ អាចត្រូវបានធ្វើឡើងតាមពេលវេលាចំពោះសេវាកម្មរបស់ក្រុមហ៊ុន SMG និងខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG។ ការផ្លាស់ប្ដូរទាំងនេះ អាចត្រូវបានធ្វើឡើងនៅគ្រប់ពេលវេលាទាំងអស់។ ខ្លឹមសារព័ត៌មានខ្លះនៅក្នុងសេវាកម្មរបស់ក្រុមហ៊ុន SMG អាចត្រូវបានផ្ដល់ជូនដោយភាគីទីបី។ ក្រុមហ៊ុន SMG ពុំទទួលខុសត្រូវសម្រាប់ខ្លឹមសារព័ត៌មានរបស់ភាគីទីពីនោះទេ។

សេវាកម្មក្រុមហ៊ុន SMG និងខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG ត្រូវបានផ្ដល់ជូនតាមមូលដ្ឋាន "ដែលមានជាក់ស្ដែង" ដោយពុំមានការធានាខុសត្រូវណាមួយនោះទេ។ ក្នុងលក្ខខណ្ឌដែលអនុញ្ញាតដោយច្បាប់ជាធរមាន ក្រុមហ៊ុន SMG ធ្វើការបដិសេធជាពិសេសចំពោះគ្រប់ការធានា និងលក្ខខណ្ឌគ្រប់ប្រភេទ រួមបញ្ចូលទាំងការធានា និងលក្ខខណ្ឌនៃភាពអាចជួយដូរបានដែលអនុវត្ត ភាពសមស្របនៃគោលបំណងជាក់លាក់ណាមួយ សិទ្ធិ ការមិនរំលោភបំពានលើភាពជាម្ចាស់កម្មសិទ្ធិ ឬសិទ្ធិរបស់ភាគីទីបី សេរីភាពពីការមិនបំផ្លិចបំផ្លាញ ការប្រើប្រាស់ដែលមានគ្មានភាពរអាក់រអួល និងការធានាគ្រប់ប្រភេទដែលអនុវត្តចាប់ពីអំឡុងពេលប្រព្រឹត្តទៅនៃការជួញដូរ ឬរបៀបប្រើប្រាស់ការជួញដូរជាដើម។

ក្រុមហ៊ុន SMG ពុំធ្វើការធានាថា (A) សេវាកម្មរបស់ក្រុមហ៊ុន SMG នឹងបំពេញតាមលក្ខខណ្ឌតម្រូវរបស់អ្នកនោះទេ (B) ប្រតិបត្តិការនៃសេវាកម្មរបស់ក្រុមហ៊ុន SMG នឹងមិនមានភាពរអាក់រអួល និងមិនមានមេរោគ ឬគ្មានបញ្ហាកំហុសកើតឡើង ឬ (C) បញ្ហាកំហុសនឹងត្រូវបានធ្វើការកែតម្រូវ។ ប្រសិនបើការប្រើប្រាស់សេវាក្រុមហ៊ុន SMG ឬខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG នាំឲ្យមានតម្រូវការជួសជុលថែទាំ ឬការផ្លាស់ប្តូរឧបករណ៍ ឬបាត់បង់អត្ថប្រយោជន៍ ឬទិន្នន័យ ក្រុមហ៊ុន SMG នឹងមិនទទួលខុសត្រូវចំពោះការខាតបង់ទាំងនោះទេ។ ការផ្តល់យោបល់តាមពាក្យសម្តី ឬជាលាយលក្ខណ៍អក្សរ ដែលអនុម័តយល់ព្រមដោយក្រុមហ៊ុន SMG ឬទីភ្នាក់ងារដែលទទួលបានការអនុញ្ញាតពីក្រុមហ៊ុន ពុំធានា និងមិនបង្កើតនូវការធានាណាមួយនៅពេលអនាគតនោះទេ។ យុត្តាធិការមួយចំនួនពុំអនុញ្ញាតឲ្យមានភាពផ្តាច់មុខនៃការធានារ៉ាប់រងដែលបានអនុវត្តនោះទេ ដែលនេះមានន័យថា ភាពផ្តាច់មុខផ្នែកខ្លះ ឬទាំងស្រុងខាងលើ អាចនឹងមិនត្រូវបានអនុវត្តចំពោះអ្នកនោះទេ។

**ការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG គឺជាហានិភ័យផ្ទាល់ខ្លួនរបស់អ្នក។** ប្រសិនបើអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុន SMG រួមទាំងខ្លឹមសារសេវាកម្មរបស់ក្រុមហ៊ុន SMG ផងដែរ ដំណោះស្រាយតែមួយគត់របស់អ្នក គឺឈប់បន្តប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG។

អ្នកឯកភាពថា ទោះក្នុងករណីណាក៏ដោយ ក៏ក្រុមហ៊ុន SMG ឬភាគីទីបីណាមួយដែលមានយោងនៅក្នុងសេវាកម្មណាមួយរបស់ក្រុមហ៊ុន SMG មិនត្រូវទទួលខុសត្រូវ (A) ចំពោះការខូចខាតគ្រប់ប្រភេទ រួមទាំងការខូចខាតដោយផ្ទាល់ ដោយប្រយោល ពិសេស ជាក់ស្តែង ចៃដន្យ មិនចំពោះ ឬជាទណ្ឌកម្ម ឬប្រភេទផ្សេងទៀតនៃការខូចខាត (រួមមានជាអាទិ៍លទ្ធកម្មនៃទំនិញ ឬសេវាកម្មជំនួស ការខាតបង់ក្នុងការប្រើប្រាស់ទិន្នន័យ ឬអត្ថប្រយោជន៍ ឬភាពរអាក់រអួលផ្នែកអាជីវកម្ម) ទោះបីបង្កឡើង និងស្ថិតនៅក្រោមនិយមន័យនៃការទទួលខុសត្រូវណាមួយក៏ដោយ ដែលកើតឡើងពាក់ព័ន្ធនឹងលក្ខខណ្ឌទាំងអស់នេះ ឬការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG និងខ្លឹមសារព័ត៌មានរបស់ខ្លួន មិនថាផ្អែកលើការធានាកិច្ចសន្យា ការរឹតបន្តឹងទំនួលខុសត្រូវ កំហុសរដ្ឋប្បវេណី (រួមបញ្ចូលទាំងការធ្វេសប្រហែស ឬសកម្មភាពផ្សេងទៀត) ឬនិយមន័យផ្លូវច្បាប់ផ្សេងទៀត បើទោះបីជាក្រុមហ៊ុន SMG ទទួលបានការណែនាំអំពីលទ្ធភាពនៃការខូចខាតទាំងនោះក៏ដោយ (B) ចំពោះការតវ៉ា ការទាមទារ ឬការខូចខាតដទៃផ្សេងទៀតទាំងអស់ដែលបង្កឡើង ឬកើតចេញពី ឬជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG របស់អ្នក។ ការបដិសេធមិនទទួលខុសត្រូវ ពុំអនុវត្តចំពោះការទទួលខុសត្រូវដែលកើតចេញពីការធ្វេសប្រហែសទាំងស្រុងរបស់ក្រុមហ៊ុនយើង ឬការប្រព្រឹត្តិខុសដោយចេតនានោះទេ ហើយនឹងមិនអនុវត្តចំពោះខ្លឹមសារដែលមានការហាមឃាត់ដោយច្បាប់ជាធរមាននោះទេ។
ប្រសិនបើក្នុងមូលហេតុណាមួយដែលការបដិសេធការធានា ឬការកំណត់ការទទួលខុសត្រូវដែលមានចែងនៅក្នុងមាត្រា 7 នេះពុំមានសុពលភាពអនុវត្ត ឬពុំអាចអនុវត្តបានដោយមូលហេតុណាមួយ នោះទំនួលខុសត្រូវជាអតិបរមារបស់ក្រុមហ៊ុន SMG សម្រាប់ប្រភេទនៃការខូចខាតណាមួយក្នុងលក្ខខណ្ឌនេះ ត្រូវកំណត់ត្រឹម $1,000។

**អ្នកទទួលស្គាល់និងឯកភាពថា ដែនកំណត់នៃទំនួលខុសត្រូវដែលមានរៀបរាប់នៅខាងលើ រួមគ្នាជាមួយនឹងបញ្ញាត្តិដទៃផ្សេងទៀតនៅលក្ខខណ្ឌទាំងនេះ ដែលកំណត់ពីទំនួលខុសត្រូវ គឺជាលក្ខខណ្ឌសំខាន់ ហើយហេតុនេះ ក្រុមហ៊ុន SMG នឹងមិនអាចផ្តល់សិទ្ធិដែលមានចែងក្នុងលក្ខខណ្ឌនេះជូនអ្នកបានទេ លើកលែងតែអ្នកមានការព្រមព្រៀងចំពោះដែនកំណត់លើទំនួលខុសត្រូវដែលបានបញ្ជាក់ពីខាងដើម។**

ប្រសិនបើអ្នកជាពលរដ្ឋរស់នៅក្នុងរដ្ឋកាលីហ័រញ៉ា អ្នកធ្វើការបដិសេធសិទ្ធិរបស់អ្នកទៅតាមក្រមរដ្ឋប្បវេណីរបស់រដ្ឋកាលីហ្វ័រញ៉ា មាត្រា 1542 ដែលចែងថា "ការលើកលែងទោស ពុំមានវិសាលភាពគ្របដណ្តប់ទៅលើបណ្តឹងទាមទារដែលដើមបណ្តឹងពុំបានដឹង ឬមានការសង្ស័យថាមានពាក់ព័ន្ធនឹងខ្លួននៅត្រឹមពេលនៃការអនុវត្តការលើកលែងទោសនោះ។ ប្រសិនបើដើមបណ្តឹងបានដឹង នោះការលើកលែងទោសនោះ ត្រូវជះឥទ្ធិពលជាសារវន្តទៅលើដំណោះស្រាយរបស់ដើមបណ្តឹងជាមួយនឹងចុងចោទ"។

## 8. សំណងការខូចខាត

អ្នកបានឯកភាពរ៉ាប់រងដោយខ្លួនឯងទៅលើការការពារ ការផ្តល់សំណង និងមិនឲ្យក្រុមហ៊ុន SMG និងភ្ញៀវ អ្នកគ្រប់គ្រង មន្ត្រី និយោជិត និងភ្នាក់ងាររបស់ក្រុមហ៊ុនមានជាប់ពាក់ព័ន្ធនឹងការខាតបង់ បំណុល បណ្តឹងតវ៉ា ចំណាត់ការ ឬការការទាមទារណាមួយឬទាំងអស់ រួមមានជាអាទិ៍ ការខាតបង់ប្រាក់កាស ការចំណាយថ្លៃចំណាយការពារក្តី រួមទាំងថ្លៃមេធាវី និងថ្លៃគណនេយ្យសមស្របណាមួយ ដែលធ្វើឡើងប្រឆាំងនឹងក្រុមហ៊ុន SMG ដោយភាគីណាមួយដែលកើតចេញពី (a) ការប្រគល់ព័ត៌មានរបស់អ្នក (b) ការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG ឬ (c) ការបំពានណាមួយរបស់អ្នកទៅលើលក្ខខណ្ឌណាមួយ សិទ្ធិរបស់ភាគីទីបី និងច្បាប់ជាធរមាន។ ប្រការស្តីពីសំណងការខូចខាតនេះ ពុំអនុវត្តចំពោះខ្លឹមសារណាដែលមានហាមឃាត់ដោយច្បាប់ជាធរមាននោះទេ។ ក្រុមហ៊ុន SMG រក្សាសិទ្ធិស្ថិតក្រោមការចំណាយរបស់ខ្លួនដើម្បីធ្វើការការពារ និងការគ្រប់គ្រងផ្តាច់មុខចំពោះបញ្ហាណាមួយដែលជាប់ពាក់ព័ន្ធនឹងសំណងដែលមានចែងក្នុងទីនេះ។ ពុំមានដំណោះស្រាយណាមួយដែលប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់ក្រុមហ៊ុន SMG ដែលត្រូវបានធ្វើឡើងដោយពុំមានការយល់ព្រមជាលាយលក្ខណ៍ជាមុនពីក្រុមហ៊ុន SMG ឡើយ។

## 9. ដំណោះស្រាយវិវាទ

លើកលែងតែវិវាទណាមួយដែលពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា ឬកាតព្វកិច្ច ឬបណ្តឹងតវ៉ាលើការបំពានណាមួយ ដែលត្រូវស្ថិតក្រោមច្បាប់សហព័ន្ធសហរដ្ឋអាមេរិក ពុំនោះសោត វិវាទរវាងអ្នកនិងក្រុមហ៊ុន SMG ដែលកើតមានឡើង ឬដែលពាក់ព័ន្ធនឹងលក្ខខណ្ឌទាំងអស់នេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងបកស្រាយ និងអនុវត្តស្របទៅតាមច្បាប់របស់រដ្ឋ Missouri (សហរដ្ឋអាមេរិក) ដោយមិនគិតអំពីខោនធី ឬតំបន់ដែលអ្នកចូលទៅប្រើប្រាស់សេវាកម្មក្រុមហ៊ុន និងមិនគិតពីភាពមិនស្របគ្នានៃគោលការណ៍ច្បាប់នោះទេ។ រាល់វិវាទទាំងអស់នេះ ត្រូវធ្វើការបកស្រាយទៅតាមច្បាប់ជាធរមានរបស់រដ្ឋ Missouri ចំពោះកិច្ចសន្យាទាំងឡាយណាដែលធ្វើឡើងនិងអនុវត្តនៅក្នុងរដ្ឋ Missouri។ អ្នក និងក្រុមហ៊ុន SMG យល់ស្របថា កតិកាសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាសម្រាប់ការលក់ទំនិញជាអន្តរជាតិ មិនអនុវត្តចំពោះការបកស្រាយ ឬការបង្កើតលក្ខខណ្ឌក្រុមហ៊ុននេះនោះទេ។



72528550_2

អ្នកនិងក្រុមហ៊ុន SMG ឯកភាពថា ភាគីនីមួយៗអាចធ្វើការប្តឹងតវ៉ាប្រឆាំងនឹងភាគីម្ខាងទៀតបានដោយផ្អែកលើមូលដ្ឋានបណ្តឹងបុគ្គលតែប៉ុណ្ណោះ ហើយមិនមែនក្នុងនាមជាដើមបណ្តឹង ឬក្នុងនាមជាសមាជិកក្រុមនៅក្នុងបណ្តឹង ឬនីតិវិធីដែលបានធ្វើឡើងជាក្រុម ឬតំណាងដោយអាណត្តិនោះទេ។

អ្នកនិងក្រុមហ៊ុន SMG ឯកភាពថា រាល់ការប្តឹងតវ៉ាទាំងអស់ នឹងត្រូវធ្វើការដោះស្រាយដោយមជ្ឈត្តកម្មដែលមានភ្ជាប់កាតព្វកិច្ចនៅក្នុងបញ្ហាដែលបានលើកឡើងនៅក្នុងមាត្រា 9 ហើយតាមរយៈនេះ អ្នកនិងក្រុមហ៊ុន SMG សូមបដិសេធសិទ្ធិក្នុងការធ្វើការទាមទារនោះនៅចំពោះតុលាការច្បាប់ណាមួយ។ សិទ្ធិដែលអ្នកអាចនឹងមាន ប្រសិនបើអ្នកដាក់បណ្តឹងទៅតុលាការ ដូចជាសិទ្ធិទទួលបានព័ត៌មានសំណុំរឿងក្តីជាដើម អាចពុំមានផ្តល់ជូន ឬត្រូវបានរឹងបន្តឹងនៅក្នុងនីតិវិធីមជ្ឈត្តកម្ម។

វិវាទណាមួយរវាងអ្នកនិងក្រុមហ៊ុន SMG និងទីភ្នាក់ងារ និយោជិត មន្ត្រី នាយកគ្រប់គ្រង នាយក សន្តតិជន អនុប្បទានិក អគ្គគាហក ឬក្រុមហ៊ុនបុគ្គសម្ព័ន្ធ កើតឡើងពី ឬពាក់ព័ន្ធនឹងលក្ខខណ្ឌក្រុមហ៊ុន និងការបកស្រាយ ឬការរំលោភបំពាន ឬការបញ្ចប់ ឬសុពលភាពនៃកិច្ចសន្យា ទំនាក់ទំនងដែលកើតចេញពីលក្ខខណ្ឌរបស់ក្រុមហ៊ុន រួមទាំងវិវាទអំពីសុពលភាព វិសាលភាពការអនុវត្តលក្ខខណ្ឌ (ហៅជារួមថា "**វិវាទក្រោមដែនគ្រប់គ្រង**") នឹងត្រូវភ្ជាប់កាតព្វកិច្ចមជ្ឈត្តកម្មនៅរដ្ឋ Missouri ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តកម្មអាមេរិក (AAA) ស្របទៅតាមវិធានរបស់ខ្លួន (រួមមានវិធាននិងនីតិវិធីសម្រាប់ វិវាទពាក់ព័ន្ធនឹងអតិថិជន) ដែលចូលជាធរមាននៅកាលបរិច្ឆេទដែលបានកំណត់។ នៅមុនពេលបង្កើតដំណើរការមជ្ឈត្តកម្ម ភាគីដែលបង្កើតមជ្ឈត្តកម្ម នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីដទៃផ្សេងទៀតយ៉ាងហោច 60 ថ្ងៃ អំពីគោលបំណងនៃការដាក់សំណើមជ្ឈត្តកម្ម។ ក្រុមហ៊ុន SMG នឹងផ្តល់នូវការជូនដំណឹងនេះតាមអ៊ីម៉ែលទៅកាន់អាសយដ្ឋានអ៊ីម៉ែលដែលអ្នកផ្តល់ជូននៅពេលអ្នកបង្កើតគណនីរបស់អ្នក ឬតាមរយៈអ៊ីម៉ែលទៅកាន់អាសយដ្ឋានអ៊ីម៉ែលអ្នកបានផ្តល់ទៅឲ្យក្រុមហ៊ុន SMG។ អ្នកត្រូវផ្តល់ការជូនដំណឹងនេះ ទៅកាន់ក្រុមហ៊ុន SMG តាមអ៊ីម៉ែល privacyofficer@smg.com។

ការទូទាត់លើថ្លៃរៀបចំឯកសារ ថ្លៃរដ្ឋបាល ឬថ្លៃមជ្ឈត្តកម្ម នឹងត្រូវស្ថិតក្រោមវិធានរបស់សមាគមន៍មជ្ឈត្តកម្មអាមេរិក (AAA)។ក៏ប៉ុន្តែ ប្រសិនបើអ្នកអាចបង្ហាញថា ការចំណាយថ្លៃមជ្ឈត្តកម្មនឹងត្រូវបានហាមឃាត់សម្រាប់អ្នក ប្រសិនប្រៀបធៀបទៅនឹងថ្លៃបណ្តឹង ក្រុមហ៊ុន SMG នឹងបង់ប្រាក់ច្រើនទៅថ្លៃរៀបចំឯកសារ ថ្លៃរដ្ឋបាល និងថ្លៃមជ្ឈត្តកម្ម ប្រសិនបើមជ្ឈត្តករកំណត់ថាចាំបាច់ដើម្បីបង្ការកុំឲ្យវិធានមជ្ឈត្តកម្មមានការហាមឃាត់ចំពោះថ្លៃចំណាយសម្រាប់អ្នក។ ប្រសិនបើអ្នកមជ្ឈត្តកម្មកំណត់ថា ការទាមទារដែលអ្នកបញ្ជាក់នៅក្នុងមជ្ឈត្តកម្ម គ្មានអត្ថន័យខ្លឹមសារ អ្នកយល់ព្រមក្នុងទូទាត់សំណងការខូចខាតដល់ក្រុមហ៊ុន SMG សម្រាប់ថ្លៃសេវាទាំងអស់ដែលពាក់ព័ន្ធនឹងមជ្ឈត្តកម្ម ដែលក្រុមហ៊ុន SMG បានបង់ជំនួសឲ្យអ្នក ដែលបើមិនដូច្នោះទេត្រូវជាប់កាតព្វកិច្ចដើម្បីបង់ប្រាក់តាមវិធានរបស់ AAA។

មជ្ឈត្តករមួយរូប នឹងត្រូវជ្រើសរើសស្របទៅតាមវិធានមជ្ឈត្តកម្មពាណិជ្ជកម្មរបស់ AAA។ មជ្ឈត្តកម្ម ត្រូវធ្វើឡើងជាភាសាអង់គ្លេស។ មជ្ឈត្តករ នឹងត្រូវមានអំណាចក្នុងការផ្តល់ដំណោះស្រាយណាមួយក៏បានដែលមាននៅក្នុងច្បាប់តុលាការ ឬដោយសមធម៌ ហើយការសម្រេចណាមួយរបស់មជ្ឈត្តករត្រូវចាត់ទុកជាស្ថាពរ

និងភ្ជាប់កាតព្វកិច្ចទៅលើភាគីនីមួយៗ និងត្រូវចាត់ទុកជាសាលក្រមរបស់តុលាការណាមួយដែលមានយុត្តាធិការ។ ក៏ប៉ុន្តែ មជ្ឈត្តករនឹងមិនមានអំណាចក្នុងចេញសេចក្តីសម្រេចលើសំណងសម្រាប់ការខូចខាតជាក់ស្តែងឬជាការដាក់ពិន័យ សម្រេចលើសិទ្ធិដែលភាគីនីមួយៗបានបដិសេធនោះទេ។ មជ្ឈត្តករ នឹងអនុវត្តតាមច្បាប់ជាធរមាន និងប្រការនានានៃលក្ខខណ្ឌរបស់ក្រុមហ៊ុន។ ការខកខានណាមួយក្នុងការអនុវត្តតាមនឹងត្រូវចាត់ទុកជាការបំពានលើអំណាចមជ្ឈត្តកម្ម និងជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យរបស់តុលាការ។ សេចក្តីសម្រេចរបស់មជ្ឈត្តករ ត្រូវមានការពន្យល់ជាលាយលក្ខណ៍អក្សរ និងត្រូវរក្សាជាការសម្ងាត់។ ក្រុមហ៊ុន SMG និងអ្នក ឯកភាពថា វិវាទដែលស្ថិតក្រោមដែនគ្រប់គ្រង នឹងត្រូវប្រគល់ទៅមជ្ឈត្តកម្មទៅតាមមូលដ្ឋានបុគ្គលតែប៉ុណ្ណោះ។ **មិនថាក្រុមហ៊ុន SMG ឬអ្នកនោះទេ សុទ្ធតែពុំមានសិទ្ធិកាត់សេចក្តីទៅលើវិវាទស្ថិតក្រោមដែនគ្រប់គ្រងថាជាបណ្តឹងជាក្រុម បណ្តឹងតំណាងដោយអាណត្តិ ឬបណ្តឹងអគ្គរដ្ឋអាជ្ញាឯកជន ហើយមជ្ឈត្តករនឹងគ្មានសិទ្ធិក្នុងបន្តចំណាត់ការដោយផ្អែកលើមូលដ្ឋានជាក្រុម តំណាងដោយអាណត្តិ ឬមូលដ្ឋាននៃអគ្គរដ្ឋអាជ្ញាឯកជននោះទេ**។ ប្រសិនបើប្រការណាមួយនៃកិច្ចព្រមព្រៀងធ្វើមជ្ឈត្តកម្មនៅមាត្រា 9 នេះត្រូវបានកំណត់ថាពុំអាចអនុវត្តបាន នោះប្រការដែលពុំអាចអនុវត្តបាននេះ នឹងត្រូវចាត់ទុកជាលក្ខខណ្ឌដែលមានទុពលភាពដោយអន្លើ ហើយលក្ខខណ្ឌមជ្ឈត្តកម្មដែលនៅសល់ នឹងត្រូវបន្តអាចអនុវត្តបាន (ប៉ុន្តែ គ្មានករណីណាមួយដែលនឹងត្រូវឲ្យមានការអនុវត្តមជ្ឈត្តកម្មជាក្រុម ជាតំណាង ឬដោយអគ្គរដ្ឋអាជ្ញាឯកជននោះទេ)។ ដោយមិនគិតពីលក្ខខន្តិកៈ ឬច្បាប់ដែលផ្ទុយពីនេះ សេចក្តីជូនដំណឹងអំពីការទាមទារណាមួយដែលកើតឡើងចេញពីលក្ខខណ្ឌក្រុមហ៊ុនដែលពាក់ព័ន្ធ ត្រូវធ្វើឡើងក្នុងរយៈពេលមួយ (1) ឆ្នាំ បន្ទាប់ពីមានការទាមទារនេះកើតឡើង ឬត្រូវបានហាមឃាត់ជារៀងរហូត។ សម្រាប់គោលបំណងនៃមាត្រា 9 នេះ លក្ខខណ្ឌរបស់ក្រុមហ៊ុន ប្រតិបត្តិការដែលពាក់ព័ន្ធ នឹងត្រូវស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ស្តីពីមជ្ឈត្តកម្មរបស់សហព័ន្ធ (Federal Arbitration Act) 9 U.S.C. sec. 1-16 (FAA)។

**ចំណាំ៖** តាមរយៈការយល់ស្របទៅនឹងលក្ខខណ្ឌរបស់ក្រុមហ៊ុន អ្នកបានឯកភាពយ៉ាងច្បាស់ថា ការទាមទារ ឬចំណាត់ការណាមួយដែលអ្នកធ្វើឡើងប្រឆាំងនឹងក្រុមហ៊ុន SMG ស្ថិតក្រោមច្បាប់នានាដែលមានយុត្តាធិការនៅក្រៅសហរដ្ឋអាមេរិក ត្រូវបានបដិសេធចោល រួមបញ្ចូលទាំងការទាមទារឬចំណាត់ការណាមួយក្រោមច្បាប់នៃប្រទេសដើមរបស់អ្នក ហើយហេតុនេះទីតាំងផ្តាច់មុខនិងច្បាប់ជាធរមានសម្រាប់ករណីវិវាទណាមួយគឺត្រូវនៅក្នុងសហរដ្ឋអាមេរិក ស្របទៅតាមលក្ខខណ្ឌនៃមាត្រា 9។

## 10. រង្វាន់

ពីពេលមួយទៅពេលមួយ ក្រុមហ៊ុន SMG ផ្តល់ឱកាសដល់អ្នកដើម្បីទទួលបានរង្វាន់ ដូចជារង្វាន់ជាពិន្ទុ ការបញ្ចុះតម្លៃ ឬផ្តល់ជូនពិសេសណាមួយ (ហៅជារួមថា "**រង្វាន់**")។ យើងនឹងធ្វើការជូនដំណឹងដល់អ្នកនៅពេលដែលរង្វាន់មានផ្តល់ជូនអ្នកតាមរយៈសេវាកម្មរបស់ក្រុមហ៊ុន SMG។ អត្ថប្រយោជន៍នៃរង្វាន់នេះ អាចមានភាពខុសគ្នា និងអាចមានរយៈពេលសុពលភាពខុសគ្នាដែរ ដូចនេះ សូមអានព័ត៌មានលម្អិតនៃរង្វាន់នីមួយៗនៅពេលអ្នកទទួលបានដំណឹងនេះ។ សម្រាប់កម្មវិធី SurveyMini រង្វាន់ជាពិន្ទុរបស់អ្នកនឹងត្រូវផុតកំណត់ក្នុងរយៈពេលកៅសិប (90) ថ្ងៃបន្ទាប់ពីគ្មានដំណើរការ។ រង្វាន់របស់អ្នក សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកតែប៉ុណ្ណោះ។ អ្នកមិនអាចផ្ទេរបន្ត ធ្វើអនុប្បទាន លក់ ជួញដូរ ឬដោះដូររង្វាន់របស់អ្នកបាននោះទេ។ លើកលែងតែតម្រូវដោយច្បាប់ បើពុំដូចនេះទេ រង្វាន់នានា នឹងមិនអាចដោះដូរជាសាច់ប្រាក់បាន

ឡើយ និងមិនអាចរួមផ្សំបញ្ចូលជាការផ្សព្វផ្សាយផលិតផល ការផ្តល់ជូន ឬការបញ្ចុះតម្លៃផ្សេងទៀតរបស់ក្រុមហ៊ុន SMG ឬអតិថិជនបានឡើយ។ ពុំមានឥណទាន ឬការប្រគល់ប្រាក់ត្រឡប់ទៅវិញ នឹងត្រូវបានធ្វើឡើងសម្រាប់ហេតុផលណាមួយបន្ទាប់ពីអ្នកប្រគល់រង្វាន់របស់អ្នកត្រឡប់ទៅវិញនោះទេ។ ក្រុមហ៊ុន SMG រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរ បញ្ចប់សេវាកម្ម ឬព្យួររង្វាន់ដែលមានផ្តល់ជូន។ អ្នកយល់ព្រមភ្ជាប់កាតព្វកិច្ចដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុន SMG ដែលត្រូវចាត់ទុកជាស្ថាពរ និងភ្ជាប់កាតព្វកិច្ចនៅគ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងរង្វាន់នេះ។

## 11. អាប់ដេតកម្មវិធីទូរសព្ទដៃ

ពីពេលមួយទៅពេលមួយ យើងអាច (តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់យើង) បង្កើត និងផ្តល់ជូនកម្មវិធីអាប់ដេតសម្រាប់កម្មវិធីទូរសព្ទដៃរបស់យើង ដែលអាចរួមបញ្ចូលនូវទិន្នន័យអាប់ប្រេ្គត ហ្វាល់កែតម្រូវកម្មវិធីកុំព្យូទ័រ (bug fixes) បណ្តុំហ្វាល់ និងកម្មវិធីកែតម្រូវកំហុស និង/ឬមុខងារថ្មីៗ (ហៅជារួមថា "**ទិន្នន័យអាប់ដេត**")។ ទិន្នន័យអាប់ដេត ក៏អាចធ្វើការកែប្រែឬលុបចោលមុខងារ និងដំណើរការកម្មវិធីជាក់លាក់ណាមួយរបស់ខ្លួនចោលទាំងស្រុងផងដែរ។ អ្នកឯកភាពថា ក្រុមហ៊ុន SMG ពុំមានកាតព្វកិច្ចក្នុងការផ្តល់ជូនទិន្នន័យអាប់ដេត ឬបន្តផ្តល់ជូន ឬបើកឲ្យដំណើរការមុខងារឬដំណើរការកម្មវិធីជាក់លាក់ណាមួយនោះទេ។

អាស្រ័យលើការកំណត់របស់ឧបករណ៍អេឡិចត្រូនិកចល័តរបស់អ្នក នៅពេលដែលឧបករណ៍អេឡិចត្រូនិកចល័តរបស់អ្នកត្រូវបានភ្ជាប់ទៅនឹងអ៊ីនធឺណិត៖ (a) ទិន្នន័យអាប់ដេត នឹងទាញយកនិងដំឡើងដោយស្វ័យប្រវត្តិ ឬ (b) អ្នកអាចទទួលបានការជូនដំណឹង ឬទទួលបានការណែនាំឲ្យទាញយក និងដំឡើងនូវទិន្នន័យអាប់ដេតទាំងនោះ។

ធ្វើការទាញយក និងដំឡើងទិន្នន័យអាប់ដេតតាមការណែនាំ។ ប្រសិនបើអ្នកមិនអាប់ដេតទេ នោះផ្នែកខ្លះនៃសេវាកម្មរបស់ក្រុមហ៊ុន SMG អាចនឹងមិនមានដំណើរការបានល្អប្រសើរនោះទេ។ អ្នកបន្តឯកភាពបន្ថែមទៀតថា គ្រប់ព័ត៌មាននៃទិន្នន័យអាប់ដេតទាំងអស់ នឹងត្រូវចាត់ទុកជាផ្នែកនៃសេវាកម្មរបស់ក្រុមហ៊ុន SMG និងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌនិងខចែងនៃលក្ខខណ្ឌទាំងអស់របស់ក្រុមហ៊ុន។

## 12. ការបង្កើតកិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិក

សកម្មភាពបញ្ជាក់របស់អ្នកចំពោះការប្រើប្រាស់ និង/ឬការចុះឈ្មោះសម្រាប់សេវាកម្មរបស់ក្រុមហ៊ុន SMG ចាត់ទុកថាអ្នកបានយល់ព្រមធ្វើការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនយើងជាលក្ខណៈអេឡិចត្រូនិក។

## 13. ដែនកំណត់ផ្នែកភូមិសាស្ត្រ/ការគ្រប់គ្រងការនាំចេញ

សេវាកម្មរបស់ក្រុមហ៊ុន SMG និងខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG គឺមានមូលដ្ឋាននៅរដ្ឋ Missouri សហរដ្ឋអាមេរិក ហើយបើទោះបីជាផ្នែកនីមួយៗត្រូវបានផ្តល់ការអនុញ្ញាតឲ្យចូលទៅប្រើប្រាស់ដោយបុគ្គលណាម្នាក់ដែលនៅក្រៅសហរដ្ឋអាមេរិកក៏ពិតមែន ក៏ប៉ុន្តែអ្នកទទួលស្គាល់ថា សម្រាប់មូលហេតុផ្លូវច្បាប់ និងប្រតិបត្តិការ អ្នកអាចពុំត្រូវបានអនុញ្ញាតឲ្យចូលទៅប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG ឬខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG នៅក្នុងយុត្តាធិការរបស់អ្នកឡើយ។ ប្រសិនបើអ្នកអាចចូលទៅប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG ឬខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG ពីខាងក្រៅមសហរដ្ឋអាមេរិក

អ្នកត្រូវមានទទួលខុសត្រូវក្នុងការអនុវត្តស្របតាមច្បាប់ក្នុងស្រុក រួមទាំងច្បាប់ក្នុងស្រុកពាក់ព័ន្ធនឹងការបញ្ចូល ការបញ្ចេញមកក្រៅ ឬការបញ្ចេញមកក្រៅសាជាថ្មីនូវខ្លឹមសារព័ត៌មានរបស់ក្រុមហ៊ុន SMG ផងដែរ។

សេវាកម្មរបស់ក្រុមហ៊ុន SMG អាចត្រូវស្ថិតក្រោមច្បាប់ស្តីពីការគ្រប់គ្រងបញ្ចេញមកក្រៅនៅក្នុងប្រទេសជាក់លាក់មួយចំនួន រួមទាំងច្បាប់រដ្ឋបាលនាំចេញសហរដ្ឋអាមេរិក និងបទប្បញ្ញត្តិដែលជាប់ពាក់ព័ន្ធនឹងច្បាប់នេះ។ អ្នកយល់ស្របថា អ្នកនឹងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិទាំងអស់នេះ ហើយអ្នកនឹងមិនបញ្ចេញ បញ្ចេញសាជាថ្មី ឬបញ្ចេញសេវាកម្មរបស់ក្រុមហ៊ុន SMG ទោះដោយផ្ទាល់ឬដោយប្រយោលក្តី ឬធ្វើឲ្យសេវាកម្មរបស់ក្រុមហ៊ុន SMG អាចចូលទៅប្រើប្រាស់បានដោយយុត្តាធិការ ឬប្រទេសណាមួយដែលការបញ្ចេញ ការបញ្ចេញសាជាថ្មី ការចេញផ្សាយត្រូវបានហាមឃាត់ដោយច្បាប់ វិធាន ឬបទប្បញ្ញត្តិ។ អ្នកឯកភាពទៀតថា អ្នកនឹងអនុវត្តទៅច្បាប់សហព័ន្ធ បទប្បញ្ញត្តិ និងវិធាននានាជាធរមាន និងអនុវត្តរាល់ការសន្យាទាំងអស់ដែលត្រូវការជាចាំបាច់ (រួមទាំងការស្នើសុំអាជ្ញាប័ណ្ណនាំចេញដែលចាំបាច់ ឬការយល់ព្រមផ្សេងទៀតពីរដ្ឋាភិបាល) នៅពេលនាំចេញ នាំចេញសាជាថ្មី បញ្ចេញ ឬធ្វើឲ្យសេវាកម្មរបស់ក្រុមហ៊ុន SMG អាចស្វែងរកបាននៅក្រៅសហរដ្ឋអាមេរិក។ បន្ថែមលើនេះ តាមរយៈការទាញយកខ្លឹមសារព័ត៌មានណាមួយរបស់ក្រុមហ៊ុន SMG អ្នកបានយល់ព្រមថា អ្នកពុំស្ថិតនៅក្នុងប្រទេសដែលមានការហាមឃាត់ចំពោះការនាំចេញនេះ ហើយអ្នកពុំស្ថិតនៅសហរដ្ឋអាមេរិកនោះទេ។ តារាងបដិសេធការបញ្ជាទិញនៃក្រសួងពាណិជ្ជកម្ម ឬ បញ្ជីឈ្មោះប្រទេសដែលបានកំណត់ជាពិសេសរបស់ក្រសួងរតនាគារជាតិអាមេរិក។

## 14. សិទ្ធិរដ្ឋាភិបាលសហរដ្ឋអាមេរិក

សេវាកម្មរបស់ក្រុមហ៊ុន SMG គឺជាសូហ្វវែរកុំព្យូទ័រពាណិជ្ជកម្ម ដូចមានកំណត់នៅ 48 C.F.R. §2.101។ តាមរយៈនេះ ប្រសិនបើអ្នកជាទីភ្នាក់ងារមួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬជាអ្នកម៉ៅការរបស់រដ្ឋាភិបាល អ្នកទទួលបានសិទ្ធិពាក់ព័ន្ធសេវាកម្មរបស់ក្រុមហ៊ុន SMG ដូចដែលទទួលបានផ្តល់ជូនដល់អ្នកប្រើប្រាស់ដទៃដែលមានអាជ្ញាប័ណ្ណ ស្របទៅតាម (a) 48 C.F.R. §227.7201 ដល់ 48 C.F.R. §227.7204 ពាក់ព័ន្ធនឹងក្រសួងការពារជាតិ និងក្រុមជាប់កិច្ចសន្យារបស់ខ្លួន ឬ (b) 48 C.F.R. §12.212 ពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណផ្សេងទៀតរបស់សហរដ្ឋអាមេរិក និងអ្នកជាប់កិច្ចសន្យារបស់ខ្លួន។

## 15. ការបញ្ចប់កិច្ចសន្យា

តាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្រុមហ៊ុន SMG អាចធ្វើការកែប្រែ ឬបញ្ចប់សេវាកម្មរបស់ក្រុមហ៊ុន SMG ឬអាចធ្វើការផ្លាស់ប្តូរ ព្យួរសេវាកម្ម ឬបញ្ចប់គណនីរបស់អ្នក ឬការចូលទៅប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG របស់អ្នក ដោយមានឬគ្មានការជូនដំណឹងដល់អ្នក នៅគ្រប់ពេលវេលាទាំងអស់សម្រាប់មូលហេតុណាមួយដោយពុំមានទទួលខុសត្រូវចំពោះអ្នក ឬភាគីទីបីណាមួយនោះទេ។ ឧទាហរណ៍ គណនីរបស់អ្នកអាចត្រូវបានបិទ ហើយការចូលទៅប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG របស់អ្នក ត្រូវបានបដិសេធ ដោយមានឬគ្មានការជូនដំណឹង ប្រសិនបើក្រុមហ៊ុន SMG មានហេតុផលដែលជឿថាអ្នកជាអនីតិជន។ នៅក្នុងឧទាហរណ៍មួយទៀត ក្រុមហ៊ុន SMG អាចបិទគណនីរបស់អ្នក ហើយសមត្ថភាពរបស់អ្នកក្នុងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG ដោយមានឬគ្មានការជូនដំណឹង ប្រសិនបើក្រុមហ៊ុន SMG មានហេតុផល

ជឿថាអ្នកបាន ផ្តល់ព័ត៌មានមិនពិត មិនពេញលេញ ឬមិនច្បាស់លាស់ ឬបានខកខាតក្នុងការអនុវត្តតាមលក្ខខណ្ឌក្រុមហ៊ុន ឬលក្ខខណ្ឌបន្ថែមណាមួយដែលមានជាធរមាន។

អ្នកបានយល់ព្រមប្រគល់ត្រឡប់ទៅវិញ ឬបំផ្លាញចោលនូវសំណៅថតចម្លងនៃឯកសារនៅលើគេហទំព័រដែលអ្នកបានបង្កើត ប្រសិនបើក្រុមហ៊ុនយើងស្នើសុំឲ្យអ្នកធ្វើការលុបចោល។

ការបញ្ចប់កិច្ចសន្យានឹងមិនកំណត់ដល់សិទ្ធិឬសំណងផ្សេងទៀតរបស់ក្រុមហ៊ុន SMG នោះទេ។ លក្ខខណ្ឌក្រុមហ៊ុនទាំងអស់នេះ នឹងត្រូវបន្តមានសុពលភាព ហើយនឹងនៅតែបន្តអាចអនុវត្តបាន មិនថាមានការកែប្រែ ការបញ្ឈប់ការប្រើប្រាស់ ការព្យួរសេវាកម្ម និង/ឬការបញ្ចប់កិច្ចសន្យានោះទេ។

**16. ការទាមទារចំពោះការបំពានលើសិទ្ធិថតចម្លង**

ក្រុមហ៊ុន SMG គោរពលើសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ។ យើងឆ្លើយតបចំពោះការជូនដំណឹងអំពីការបំពានកិច្ចសន្យាដែលជាប់ការចោទប្រកាន់ ដែលតម្រូវដោយច្បាប់ស្តីពីសិទ្ធិថតចម្លងសហសវត្សរ៍ផ្នែកឌីជីថលសហរដ្ឋអាមេរិក (US Digital Millennium Copyright Act) (ហៅកាត់ថា "**DMCA**") ដូចជាតាមរយៈដកយកចេញ ឬមិនឲ្យចូលទៅប្រើប្រាស់ឯកសារណាមួយដែលមានការទាមទារដែលស្ថិតក្រោមសកម្មភាពនៃការរំលោភបំពាននេះ ប្រសិនបើអាចធ្វើបាន។

ប្រសិនបើអ្នកមានជំនឿជាក់ល្អថា ស្នាដៃរបស់អ្នកត្រូវបានថតចម្លងក្នុងលក្ខណៈដែលនាំឲ្យមានការរំលោភបំពានលើសិទ្ធថតចម្លង ឬសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកត្រូវបានគេបំពាននៅក្នុងឬតាមរយៈសេវាកម្មរបស់ក្រុមហ៊ុន SMG សូមផ្ញើការទាមទាររបស់អ្នក ឬការជូនដំណឹងអំពីការរំលោភបំពានទៅកាន់ភ្នាក់ងារ DMCA តាមរយៈ៖

DMCA Agent
Service Management Group, LLC
1737 McGee Street
Kansas City, MO 64108

ឬផ្ញើអ៊ីម៉ែល៖

privacyofficer@smg.com

ការជូនដំណឹងរបស់អ្នក ត្រូវរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

a. ហត្ថលេខាផ្ទាល់ដៃ ឬហត្ថលេខាអេឡិចត្រូនិកនៃបុគ្គលដែលទទួលបានការអនុញ្ញាតឲ្យអនុវត្តការងារជំនួសឲ្យម្ចាស់ដែលមានសិទ្ធិផ្តាច់មុខ ដែលត្រូវបានចោទប្រកាន់ពីការរំលោភបំពាននេះ។
b. ការកំណត់អត្តសញ្ញាណនៃស្នាដៃដែលជាប់សិទ្ធិថតចម្លង ដែលត្រូវបានប្តឹងតវ៉ាថាត្រូវបានគេបំពាន ឬប្រសិនបើមានស្នាដៃជាប់សិទ្ធិថតចម្លងច្រើននៅលើគេហទំព័រតែមួយត្រូវបានដាក់នៅក្នុងការជូនដំណឹងតែមួយ បញ្ជីអ្នកតំណាងនៃស្នាដៃនោះនៅគេហទំព័រនោះ។

c. កំណត់អត្តសញ្ញាណសម្ភារៈដែលត្រូវបានប្តឹងតវ៉ាថាត្រូវបានរំលោភបំពាន និងស្ថិតក្រោមសកម្មភាពនៃការរំលោភបំពាន ហើយត្រូវការដកចេញ ឬការចូលទៅប្រើប្រាស់ដែលត្រូវបានគេបិទមិនឲ្យដំណើរការ និងព័ត៌មានដែលមានការគ្រប់គ្រងដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនផ្តល់សេវាកម្មដើម្បីកំណត់ទីតាំងឯកសារនោះ។
d. ព័ត៌មានដែលគ្រប់គ្រងដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនផ្តល់សេវាកម្មធ្វើការទាក់ទងទៅកាន់ភាគីដាក់ពាក្យប្តឹង ដូចជាអាសយដ្ឋាន លេខទូរសព្ទ និង (ប្រសិនបើមាន) អាសយដ្ឋានប្រៃសណីយ៍អេឡិចត្រូនិកដែលភាគីដាក់ពាក្យបណ្តឹងអាចត្រូវបានគេទាក់ទងទៅ។
e. របាយការណ៍ដែលភាគីដាក់ពាក្យបណ្តឹង មានការជឿជាក់ថា ការប្រើប្រាស់ឯកសារក្នុងលក្ខណៈដែលការប្តឹងនេះ ពុំទទួលបានការអនុញ្ញាតដោយម្ចាស់សិទ្ធិថតចម្លង ទីភ្នាក់ងារ ឬច្បាប់។ និង
f. របាយការណ៍ដែលព័ត៌មាននៅក្នុងការជូនដំណឹង គឺត្រឹមត្រូវច្បាស់លាស់ និងស្ថិតក្រោមទោសទណ្ឌនៃការផ្តល់ព័ត៌មានមិនពិត ភាគីដាក់ពាក្យប្តឹង ទទួលបានការអនុញ្ញាតដើម្បីអនុវត្តការងារជំនួសឲ្យម្ចាស់សិទ្ធិផ្តាច់មុខដែលត្រូវបានជាប់ចោទពីការរំលោភបំពាន។

ភ្នាក់ងារ DMCA របស់យើងនឹងឆ្លើយតបចំពោះសេចក្តីជូនដំណឹងនិងការសាកសួរណាដែលអនុលោមទៅតាមលក្ខខណ្ឌតម្រូវរបស់ DMCA។ សូមអាន www.copyright.gov សម្រាប់ព័ត៌មានបន្ថែម។

## 17. ព័ត៌មានសម្រាប់ពលរដ្ឋរស់នៅរដ្ឋកាលីហ្វ័រញ៉ា

ស្ថិតក្រោមក្រមរដ្ឋប្បវេណីរដ្ឋកាលីហ្វ័រញ៉ា មាត្រា 1789.3 យើងត្រូវបានតម្រូវឲ្យផ្តល់ជូនដល់ពលរដ្ឋកាលីហ្វ័រញ៉ានូវព័ត៌មានស្តីពីសិទ្ធិអ្នកប្រើប្រាស់ជាក់លាក់មួយចំនួនដូចខាងក្រោម៖

a. សេវាកម្មរបស់ក្រុមហ៊ុន SMG ត្រូវបានកាន់កាប់ និង/ឬប្រតិបត្តិការដោយក្រុមហ៊ុន Service Management Group, LLC, 1737 McGee Street, Kansas City, MO 64108។ លេខទូរសព្ទសម្រាប់ទំនាក់ទំនងក្រុមហ៊ុន SMG លេខ 1-800-764-0439។
b. លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ បើពុំដូចនោះទេ សេវាកម្មរបស់ក្រុមហ៊ុន SMG ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ។
c. ដើម្បីដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងសេវាកម្មរបស់ក្រុមហ៊ុន SMG ឬដើម្បីទទួលបានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន SMG សូមផ្ញើលិខិតមួយច្បាប់ទៅក្រុមហ៊ុន Service Management Group, LLC, ផ្ញើជូន៖ Data Protection Officer, 1737 McGee Street, Kansas City, MO 64108 ឬទំនាក់ទំនងយើងតាមរយៈអ៊ីម៉ែលនៅ privacyofficer@smg.com (ដោយប្រើប្រាស់ "សំណើសុំពលរដ្ឋក្នុងរដ្ឋកាលីហ្វ័រញ៉ា" ជាកម្មវត្ថុនៃការស្នើសុំតាមអ៊ីម៉ែល)។ អ្នកក៏អាចធ្វើការទំនាក់ទំនងទៅកាន់អង្គភាពជំនួយផ្នែកបណ្តឹង (Complaint Assistance Unit) នៃអង្គភាពសេវាអតិថិជនរដ្ឋកាលីហ្វ័រញ៉ានៃនាយកដ្ឋានកិច្ចការអតិថិជន ជាលាយលក្ខណ៍អក្សរដែលមានអាសយដ្ឋានស្ថិតនៅ 400 R Street, Suite 1080, Sacramento, California 95814 ឬតាមទូរសព្ទតាមរយៈលេខ 916.445.1254 ឬ 800.952.5210។

**18. លក្ខខណ្ឌផ្សេងៗ**

a. លក្ខខណ្ឌទាំងអស់នេះ និងគោលការណ៍ស្តីពីសិទ្ធិឯកជនភាព ដែលមានរៀបរាប់នៅគេហទំព័រផ្សេងៗ មានផ្ទុកទៅដោយការយោគយល់គ្នាទាំងស្រុង តាមរយៈនិងក្នុងចំណោមក្រុមហ៊ុន SMG និងអ្នកពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងលក្ខខណ្ឌនេះ។

b. លក្ខខណ្ឌក្រុមហ៊ុន ត្រូវបានសរសេរជាភាសាអង់គ្លេស។ កិច្ចសន្យាជាភាសាអង់គ្លេស នឹងគ្រប់គ្រងលើគ្រប់ផ្នែកទាំងអស់។ ឯកសារណាមួយនៃកិច្ចសន្យានេះធ្វើឡើងជាភាសាផ្សេងទៀត នឹងត្រូវបង្កើតឡើងសម្រាប់ជាការងាយស្រួលប៉ុណ្ណោះ និងមិនត្រូវភ្ជាប់កាតព្វកិច្ចចំពោះភាគីណាមួយនោះទេ។

c. លក្ខខណ្ឌទាំងអស់នេះ ប្រើប្រាស់សម្រាប់ជាអត្ថប្រយោជន៍ ហើយនឹងត្រូវភ្ជាប់កាតូកិច្ចចំពោះសន្តតិជន និងអនុប្បទានិករបស់ក្រុមហ៊ុន SMG។

d. លក្ខខណ្ឌទាំងអស់នេះ អាចត្រូវបានកំណត់ដោយក្រុមហ៊ុន SMG ប៉ុន្តែអាចមិនត្រូវប្រគល់សិទ្ធិបន្តគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុន SMG នោះទេ។

e. ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌក្រុមហ៊ុន ពុំអាចអនុវត្តបាន ឬគ្មានសុពលភាព នោះលក្ខខណ្ឌផ្សេងទៀត នឹងនៅបន្តមានសុពលភាពអនុវត្តដដែល ប្រសិនបើប្រការដែលមិនអាចអនុវត្តបាន ឬគ្មានសុពលភាពនោះ មិនត្រូវបានប្រើប្រាស់។

f. ប្រសិនបើក្រុមហ៊ុន SMG ខកខានមិនអនុវត្តកាតព្វកិច្ចស្ថិតក្រោមលក្ខខណ្ឌក្រុមហ៊ុន ហើយភាគីផ្សេងទៀតពុំបានអនុវត្តកាតព្វកិច្ច ការខកខានមិនអនុវត្តក្នុងកាលៈទេសណាមួយ នឹងមិនត្រូវចាត់ទុកជាការបដិសេធកាតព្វកិច្ច ហើយនឹងមិនត្រូវរារាំងដល់ការអនុវត្តក្នុងកាលៈទេសៈផ្សេងទៀតឡើយ។

g. ពុំមានខ្លឹមសារណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌរបស់ក្រុមហ៊ុននេះ នឹងត្រូវបានចាត់ទុកភាគីក្រុមហ៊ុន SMG ឬអ្នកថាជាភ្នាក់ងារ ឬអ្នកតំណាងឲ្យគ្នាទៅវិញទៅមក ឬចាត់ទុកថាជាផ្នែកនៃការវិនិយោគរួមគ្នា ឬជាដៃគូអាជីវកម្មនោះទេ។

h. ប្រសិនបើ ក្រុមហ៊ុន SMG ឬអ្នកត្រូវបានរារាំងមិនឲ្យអនុវត្តការងារ ឬមិនអាចបំពេញកាតព្វកិច្ចណាមួយស្ថិតក្រោមលក្ខខណ្ឌក្រុមហ៊ុន ដោយសារមូលហេតុណាមួយលើសពីលទ្ធភាពគ្រប់គ្រងបាននៃភាគីដែលលុបចោលប្រការនេះ ការអនុវត្តការងាររបស់ភាគីដែលរងប៉ះពាល់ នឹងត្រូវបន្តសម្រាប់រយៈពេលនៃការពន្យារពេល ឬអសមត្ថភាពក្នុងអនុវត្តការងារទៅតាមមូលហេតុនោះ។

i. ចំណងជើង និងចំណងជើងរង គឺសម្រាប់ជាភាពងាយស្រួលតែប៉ុណ្ណោះ។

## តើអ្នកមានសំណួរអ្វីដែរឬទេ?

ប្រសិនបើអ្នកមានសំណួរណាមួយអំពីលក្ខខណ្ឌនៃការប្រើប្រាស់នេះ ឬសេវាកម្មរបស់ក្រុមហ៊ុន SMG សូមទំនាក់ទំនងតាម privacyofficer@smg.com។

អ្នកក៏អាចសរសេរលិខិតមកកាន់យើងបានផងដែរនៅ៖

Service Management Group, LLC

ជូនចំពោះ៖ Data Protection Officer

1737 McGee Street

Kansas City, MO 64108

®/TM trademarks © Service Management Group, LLC 2017. រក្សាសិទ្ធិគ្រប់យ៉ាង។